# រចនាសម្ព័ន្ធដឹកនាំ
# គ្រប់គ្រងរបស់បេឡាជាតិរបបសន្តិសុខសង្គម

**ក្រសួងអាណាព្យាបាល**

**ក្រុមប្រឹក្សាភិបាល**

**នាយក**

**នាយករង**

**ការិយាល័យប្រតិបត្តិ ចំនួន០៨**

**ការិយាល័យប្រតិបត្តិតាមបណ្តារាជធានី-ខេត្ត**



# សមាសភាពក្រុមប្រឹក្សាភិបាលនៃបេឡាជាតិ របបសន្តិសុខសង្គម

## ក្រសួងអាណាព្យាបាល


ឯកឧត្តម **សេង សក្ដា**


លោក **អ៊ុក សមវិទ្យា**


ឯកឧត្តម **ម៉ម អំណត់**


លោក **នង ពិសិដ្ឋ**


លោក **ឡូ វាសនាគីរី**

## តំណាងសមាគមនិយោជក


ឯកឧត្តមឧកញ៉ាបណ្ឌិត **ឈាង សុធី**


លោក **វ៉ាន់ ស៊ូអៀង**

## តំណាងសមាគមកម្មករនិយោជិត


លោក **អាត់ ធន់**


លោក **ហេង ប៊ុនឈុន**

## មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុនិងគណនេយ្យករ


លោក **សេង ចំរើន**


លោក **អេត បុរ៉ាត់**

ឯកឧត្តម **សេង សក្ដា** ជាប្រធាន
តំណាងក្រសួង
ការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ

លោក **អ៊ុក សមវិទ្យា**
ជាសមាជិកស្វ័យប្រវត្តិ

ឯកឧត្តម **ម៉ម អំណត់** ជាសមាជិក

លោក **នង ពិសិដ្ឋ** ជាសមាជិក

លោក **ឡូ វាសនាគីរី** ជាសមាជិក

ឯកឧត្តមឧកញ៉ាបណ្ឌិត **ឈាង សុធី**
ជាសមាជិក

លោក **វ៉ាន់ ស៊ូអៀង** ជាសមាជិក

លោក **អាត់ ធន់** ជាសមាជិក

លោក **ហេង ប៊ុនឈុន** ជាសមាជិក

លោក **សេង ចំរើន** ជាមន្ត្រី
ត្រួតពិនិត្យហិរញ្ញវត្ថុ

លោក **អេត បុរ៉ាត់** ជាគណនេយ្យករ

# សមាសភាពគណៈកម្មការដោះស្រាយវិវាទ ឬបណ្តឹង ប.ស.ស



លោក ស៊ី សោភ័ណ



លោក សោម ចំណាន



លោក វង្ស សុវណ្ណ



លោក ម៉េង ហុង



លោក ជាវ ប៊ុនរិទ្ធ



លោក កាំង ម៉ូនីកា



លោក ជាតិ ខេមរា



លោក ឯក សុភក្តិ



លោក សោម អ៊ុន

## គណៈកម្មការវេជ្ជសាស្ត្រ ប.ស.ស



លោកវេជ្ជ. ប៉ុក ភ័ណ្ណថាត



លោកវេជ្ជ. សុខ ស្រ៊ុន



លោកវេជ្ជ. កុល ហៀវ



លោកវេជ្ជ. ហាន់ ឧញ្ញកុណា



លោកវេជ្ជ. សុខ ប៊ុ

## គណៈកម្មការដោះស្រាយវិវាទឬបណ្តឹងនៃប.ស.ស

| | | |
|---|---|---|
| លោក | **ស៊ី សោភ័ណ** | ជាប្រធាន |
| លោក | **សោម ចំណាន** | ជាសមាជិក |
| លោក | **វង្ស សុវណ្ណ** | ជាសមាជិក |
| លោក | **ម៉េង ហុង** | ជាសមាជិកបំរុង |
| លោក | **ជាវ ប៊ុនរិទ្ធ** | ជាសមាជិកបំរុង |
| លោក | **កាំង ម៉ូនីកា** | ជាសមាជិកបំរុង |
| លោក | **ជាតិ ខេមរា** | ជាសមាជិកបំរុង |
| លោក | **ឯក សុភក្តិ** | ជាសមាជិកបំរុង |
| លោក | **សោម អ៊ុន** | ជាសមាជិកបំរុង |

## គណៈកម្មការវេជ្ជសាស្ត្រនៃប.ស.ស

| | | |
|---|---|---|
| លោកវេជ្ជ. | **ប៉ុក ភ័ណ្ណថាត** | ជាប្រធាន |
| លោកវេជ្ជ. | **សុខ ស្រ៊ុន** | ជាអនុប្រធាន |
| លោកវេជ្ជ. | **កុល ហៀវ** | ជាសមាជិក |
| លោកវេជ្ជ. | **ហាន់ ឧញ្ញកុណា** | ជាសមាជិកបំរុង |
| លោកវេជ្ជ. | **សុខ ប៊ុ** | ជាសមាជិកបំរុង |

## រចនាសម្ព័ន្ធព្រឹត្តិបត្រ ប.ស.ស

| | | |
|---|---|---|
| ចាត់ចែង | លោក | **អ៊ុក សមវិទ្យា** |
| និពន្ធនាយក | លោក | **ជាវ ប៊ុនរិទ្ធ** |
| និពន្ធនាយករង | លោក | **ជៀក លីម៉េង** |
| លេខានិពន្ធ | កញ្ញា | **ជាក់ តី** |
| ក្រុមព័ត៌មាន | លោក | **ឃួង ច័ន្ទតារា** |
| | លោក | **ឯម រតន៍មុន្នី** |
| ផ្នែកកុំព្យូទ័រ | លោក | **លី សុខា** |
| | លោក | **ផេង សុវណ្ណា** |
| | លោក | **ផង់ មល្លិកា** |

ផ្នែកទទួលផ្សាយពាណិជ្ជកម្ម

លោក **ហេង សុផាន់ណារិទ្ធ**

លោក **លី វណ្ណា**

# ការិយាល័យ ប.ស.ស តាមបណ្ដារាជធានី-ខេត្ត

- **ការិយាល័យ ប.ស.ស ថ្នាក់កណ្ដាល ( រាជធានីភ្នំពេញ)**
  អាសយដ្ឋាន : អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
  ទូរស័ព្ទ : ០២៣ ៩៩៨ ៤១៧ ,៩៩៨ ៤១៨ , ៩៩៨ ៤១៩ ទូរសារ ០២៣ ៨៨២ ៦២៣
  គេហទំព័រ :
  សារអេឡិចត្រូនិច :
- **ការិយាល័យ ប.ស.ស ខេត្តស្វាយរៀង**
  អាសយដ្ឋាន : ផ្ទះលេខ A ២ ផ្លូវជាតិលេខ១ ភូមិបាវិតលើ សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង
  ទូរស័ព្ទ : ០៤៤ ៩៤ ៦២ ៦៦ ,០៧៧ ៦៦ ៣២ ១៤
  សារអេឡិចត្រូនិច :
- **ការិយាល័យ ប.ស.ស ខេត្តព្រះសីហនុ**
  អាសយដ្ឋាន : ផ្ទះលេខ១១៩ A ភូមិ២ សង្កាត់៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
  ទូរស័ព្ទ : ០៣៤ ៩៣ ៤៦ ០៦ ,០៧៧ ៦៦ ៣២ ១៥
  សារអេឡិចត្រូនិច :
- **ការិយាល័យ ប.ស.ស ខេត្តកំពង់ឆ្នាំង**
  អាសយដ្ឋាន : ភូមិម៉ុងបារាំង សង្កាត់ប្អេរ ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង
  ទូរស័ព្ទ : ០២៦ ៩៨ ៨៨ ៩១ ,០៧៧ ៦៦ ៣២ ១៦
  សារអេឡិចត្រូនិច :
- **ការិយាល័យ ប.ស.ស ខេត្តសៀមរាប**
  អាសយដ្ឋាន : ផ្ទះលេខក១០ ភូមិក្រញ៉ាំងសេះ សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប
  ទូរស័ព្ទ : ០៦៣ ៩៦ ៥៩ ៣៤ ,០៧៧ ៦៦ ៣២ ១៧
  សារអេឡិចត្រូនិច :
- **ការិយាល័យ ប.ស.ស ខេត្តបន្ទាយមានជ័យ**
  អាសយដ្ឋាន : ផ្ទះលេខ ២៥ ផ្លូវយោយម៉ៅ ភូមិបាលិលេយ្យ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ
  ទូរស័ព្ទ : ០៥៤ ៩៦ ៧៤ ៤៩ ,០៧៧ ៦៦ ៣២ ១៨
  សារអេឡិចត្រូនិច :
- **ការិយាល័យ ប.ស.ស ខេត្តកំពង់ចាម**
  អាសយដ្ឋាន : ភូមិ ៤ សង្កាត់វាលវង់ ក្រុងកំពង់ចាម ខេត្តកំពង់ចាម
  ទូរស័ព្ទ : ០៤២ ៦៥២១ ៩៩៩/០៧៧ ៩៩ ០០ ៤៨
  សារអេឡិចត្រូនិច :
- **ការិយាល័យ ប.ស.ស ខេត្តក្រចេះ**
  អាសយដ្ឋាន : ភូមិអូរឫស្សី ១ សង្កាត់អូរឫស្សី ក្រុងក្រចេះ ខេត្តក្រចេះ
  ទូរស័ព្ទ :
  សារអេឡិចត្រូនិច :
- **ការិយាល័យ ប.ស.ស ខេត្តកំពង់ស្ពឺ**
  អាសយដ្ឋាន : ផ្ទះលេខ ៣៦A ភូមិស្វាយជ្រុំ ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្ដាល
  ទូរស័ព្ទ : ០៧៧ ៥៧០ ៩០៧
  សារអេឡិចត្រូនិច :
- **ការិយាល័យ ប.ស.ស ខេត្តកណ្ដាល**
  អាសយដ្ឋាន : ផ្ទះលេខ១ ភូមិដើមមៀន សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្ដាល
  ទូរស័ព្ទ : ០៧៧ ៥៧០ ៩០៣
  សារអេឡិចត្រូនិច :
- **ការិយាល័យ ប.ស.ស ខេត្តព្រៃវែង**
  អាសយដ្ឋាន : ភូមិលេខ ១ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង
  ទូរស័ព្ទ : ០៧៧ ៥៧ ០២ ០៩
  សារអេឡិចត្រូនិច :
- **ការិយាល័យ ប.ស.ស ខេត្តតាកែវ**
  អាសយដ្ឋាន : ភូមិ ២ សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ
  ទូរស័ព្ទ : ០៩៧ ២០០២ ៨៥២
  សារអេឡិចត្រូនិច :

# តើបេឡាជាតិរបបសន្តិសុខសង្គមជាអ្វី?

***"បេឡាជាតិរបបសន្តិសុខសង្គម"*** *សរសេរកាត់ថា "ប.ស.ស" គឺជា "គ្រឹះស្ថានសាធារណៈរដ្ឋបាល" ដែលមានបេសកកម្មបម្រើ សេវាសាធារណៈមានលក្ខណៈសង្គម ស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ* ***និងអាណាព្យាបាលហិរញ្ញវត្ថុ នៃក្រសួង*** *សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ក្រុមប្រឹក្សាភិបាល* ***នៃ "ប.ស.ស" មានសមាសភាពត្រីភាគី ដែលក្នុងនោះមានតំណាងរដ្ឋាភិបាល តំណាងសមាគមនិយោជក និងតំណាង*** *សមាគមកម្មករនិយោជិត។*

*"ប.ស.ស" ត្រូវបានបង្កើតឡើងដោយ* ***អនុលោមតាម "ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិត*** *នៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ" ដោយធានាការពារ ផ្នែកប្រាក់សោធន ផ្នែកហានិភ័យការងារ និងផ្នែកផ្សេងៗទៀត ផ្អែកតាមស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ចជាតិ។*

*ការធានារ៉ាប់រងសន្តិសុខសង្គមមានសារៈសំខាន់ខ្លាំងណាស់នៅក្នុងបរិបទដែលប្រទេសកម្ពុជាមានការរីកចម្រើនលើគ្រប់វិស័យ ដោយបានផ្តល់នូវការគាំពារសង្គមសម្រាប់ប្រជាជនកម្ពុជា និយាយជារួម និងដោយឡែកចំពោះកម្មករនិយោជិតដែលបម្រើការងារនៅតាមសហគ្រាស គ្រឹះស្ថាន ដោយផ្អែកលើទស្សនាទាននៃការចែករំលែក និងគោលការណ៍សាមគ្គីធម៌ក្នុងសង្គមធានាបាននូវសន្តិសុខ ប្រាក់ចំណូលពេលគឺមានន័យថាគ្មានសមាជិកសង្គមណាម្នាក់ធ្លាក់ទៅក្នុងហានិភ័យដោយមិនមានការធានារ៉ាប់រងនោះឡើយ និងមានន័យម្យ៉ាងទៀតថាជាការរួមចំណែកសម្រាលបន្ទុកសង្គមផងដែរ។*

***(ដកស្រង់ចេញពីសុន្ទរកថារបស់លោកនាយក ប.ស.ស)***

## មាតិកា ព្រឹត្តិបត្រ បេឡាជាតិរបបសន្តិសុខសង្គម


- តើបេឡាជាតិរបបសន្តិសុខសង្គមជាអ្វី? 5
- តួនាទី និងសមត្ថកិច្ចរបស់បេឡាជាតិរបបសន្តិសុខសង្គម 6
- ក្រុមប្រឹក្សាភិបាល ប.ស.ស ក្នុងសកម្មភាពដាក់កែងច្បាប់ 7
- រាជធានី-ខេត្តមួយចំនួនត្រូវបានដាក់ឱ្យអនុវត្តរបបធានារ៉ាប់រង 8
- ការចុះបញ្ជីការសហគ្រាស គ្រឹះស្ថាននៅ ប.ស.ស គឺជា 9
- អត្រាកំណត់ភាគទាន និងរបៀបបង់ភាគទាននៃការបង់ភាគទានសម្រាប់ 10
- អំពីគាំពារការពិការហានិភ័យការងារ 12
- សកម្មភាពអនុវត្តការងារជាក់ស្តែងរបស់ ប.ស.ស 14
- កិច្ចព្រមព្រៀងនិងអនុស្សរណៈនៃការយោគយល់គ្នារវាង 17
- វេទិកាសាធារណៈផ្សព្វផ្សាយ 19
- ប្រកាសស្តីពី គាំពារការពិការហានិភ័យការងារ 23
- អនុក្រឹត្យស្តីពី ប្រតិទិនឈប់សម្រាកការងាររបស់មន្ត្រីរាជការ 33
- ប្រកាសស្តីពី ការឈប់បុណ្យដែលមានប្រាក់ឈ្នួលប្រចាំឆ្នាំ 36
- ប្រកាសស្តីពី ការកែសម្រួលប្រការ ៧ និងប្រការ ៩ នៃប្រកាស 38
- ប្រកាសស្តីពី ការកែសម្រួលប្រការ ៨ និងប្រការ ១០ នៃប្រកាស 41
- ប្រកាសរដ្ឋមន្ត្រីក្រសួងព័ត៌មាន 44








# តួនាទីនិងសមត្ថកិច្ច របស់បេឡាជាតិរបបសន្តិសុខសង្គម


ឯកឧត្តម វង សូត


លោក អ៊ិក សមវិទ្យា

លោក **អ៊ិក សមវិទ្យា** នាយកបេឡាជាតិរបបសន្តិសុខសង្គម ធ្លាប់បានអះអាងកន្លងមកថា អង្គភាពបេឡាជាតិរបបសន្តិសុខសង្គម គឺជាស្ថាប័ន រដ្ឋមួយដែលមានបេសកកម្មទាក់ទង និងការធានារ៉ាប់រងសង្គម។

លោកនាយកបានឱ្យដឹងថា រដ្ឋាភិ-បាលក៏ដូចជាអង្គការនីតិបញ្ញត្តិបានអនុម័តច្បាប់មួយហៅថា ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ មានន័យថា អ្នកណាក៏ដោយឱ្យតែស្ថិតនៅក្រោមដំបូលនៃច្បាប់ការងារត្រូវទទួលបាននូវការធានារ៉ាប់រង និងការពារពីសំណាក់ស្ថាប័នរដ្ឋមួយនេះ។

លោកនាយកបានបញ្ជាក់ថែមថា ដែនសមត្ថកិច្ចក្នុងការធានារ៉ាប់រងរបស់ ប.ស.ស គឺគ្របដណ្តប់ លើ៣ផ្នែកធំៗរួមមាន ៖

១-ធានារ៉ាប់រងលើការផ្តល់ប្រាក់សោធននិវត្តន៍ដែល ចែកចេញជា -ប្រាក់សោធនសម្រាប់ជរាពាធ -សោធនទព្វលភាព -សោធនសម្រាប់អ្នកស្ថិតក្នុងបន្ទុក។

២-ធានារ៉ាប់រងលើផ្នែកហានិភ័យការងារ

៣-ធានារ៉ាប់រងលើផ្នែកដទៃទៀតដែលមិនមានចែងច្បាស់លាស់ដូចជា ៖ ការថែទាំសុខភាព ពិការភាព ទ្រទ្រង់បន្ទុកគ្រួសារ ...។ល។

ទាក់ទងនឹងដែនសមត្ថកិច្ចរបស់ ប.ស.ស នេះ **ឯកឧត្តម វង សូត** រដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ បានថ្លែងថាអង្គភាពបេឡាជាតិរបបសន្តិសុខសង្គមជាគ្រឹះស្ថានសាធារណៈរដ្ឋបាល មានតួនាទីគ្រប់គ្រងលើផ្នែករបបធានារ៉ាប់រងហានិភ័យការងារ ការថែទាំសុខភាពរបបប្រាក់សោធន និងរបបធានារ៉ាប់រងផ្សេងៗទៀត។ ឯកឧត្តម រដ្ឋមន្ត្រី បានលើកឡើងថា ប្រព័ន្ធសន្តិសុខសង្គមបានចាប់បដិសន្ធិនៅឆ្នាំ១៩៥៥ ដោយ ព្រះរាជក្រឹត្យលេខ៥៥និងលេខ៣០៦។ ក្រោយរបបប្រល័យពូជសាសន៍បានបញ្ចប់ទៅជាបន្តបន្ទាប់ យើងបានកសាងច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និងបានប្រកាសឱ្យប្រើនៅឆ្នាំ២០០២ រហូតមកដល់បច្ចុប្បន្ននេះ។

**ឯកឧត្តម សេង សក្កដា** ប្រធានក្រុមប្រឹក្សាភិបាលនៃ ប.ស.ស បានអះអាងថា បេឡាជាតិរបបសន្តិសុខសង្គមមានក្រុមប្រឹក្សាភិបាលដែលចូល រួមដោយត្រីភាគីមកពីខាងរដ្ឋាភិបាល សមាគមនិយោជក និងសមាគមកម្មករនិយោជិត។




**ឯកឧត្តម សេង សក្កដា** បានឱ្យដឹងទៀតថា បេឡាជាតិរបបសន្តិសុខសង្គមកាលពីដើមជាអតីតនាយកដ្ឋានសន្តិ-

តទៅទំព័រ ១៥

# ក្រុមប្រឹក្សាភិបាល ប.ស.ស ក្នុង សកម្មភាពតាក់តែងច្បាប់




យ៉ាងហោចណាស់ក៏មានកិច្ចប្រជុំប្រមាណជាង ២១ លើករួចមកហើយដែរ ដែលក្រុមប្រឹក្សាភិបាលនៃ ប.ស.ស បានរៀបចំ ឡើងដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាង អនុក្រឹត្យ ប្រកាស សេចក្តីសម្រេចនិង គោលនយោបាយប្រតិបត្តិមួយចំនួនទៀតនោះ។ នេះបើផ្អែកតាមរបាយការណ៍ផ្លូវការរបស់ក្រុមប្រឹក្សាភិបាលនៃ ប.ស.ស។

ក្នុងរបាយការណ៍នោះបានបញ្ជាក់ឱ្យដឹងថាលទ្ធផលដែលទទួលបានពីកិច្ចប្រជុំនោះរួមមាន ៖

-អនុក្រឹត្យស្តីពីការតែងតាំងសមាស ភាពក្រុមប្រឹក្សាភិបាលនៃប.ស.ស អាណ្ណត្តិទី២

-ប្រកាសអន្តរក្រសួង ស្តីពីការកំណត់លាភការមុខងារសមាជិកក្រុមប្រឹក្សាភិបាលនៃ ប.ស.ស ។

-ប្រកាសរួម ស្តីពីការជូនដំណឹងហានិភ័យការងារ។

-ប្រកាសស្តីពីការបង្កើតសញ្ញារបស់ ប.ស.ស

-ប្រកាសរួមស្តីពីការបង្កើតគណៈកម្មការវេជ្ជសាស្រ្តនៃ ប.ស.ស។

-ប្រកាសស្តីពីរចនាសម្ពន្ធ័គ្រប់គ្រង ប.ស.ស

-ប្រកាសស្តីពីការកំណត់ដំណាក់កាលនិងវិសាលភាពនៃការអនុវត្តន៍របបធានារ៉ាប់រងហានិភ័យការងារ។

-ប្រកាសស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុង ប.ស.ស។

-ប្រកាសស្តីពីការកំណត់អត្រាភាគទានសម្រាប់ផ្នែកហានិភ័យការងារ។

-ប្រកាសស្តីពីតាវកាលិកហានិភ័យការងារ

តទៅទំព័រ ១៥



# រាជធានី-ខេត្តមួយចំនួនត្រូវបានដាក់ឱ្យអនុវត្ត
# របបធានារ៉ាប់រងហានិភ័យការងាររបស់ ប.ស.ស



*លោក ស៊ុំ សោភ័ណ ឡើងធ្វើបទបង្ហាញ*

មានរាជធានី-ខេត្តសំខាន់មួយចំនួននៅកម្ពុជា ត្រូវបានដាក់ឱ្យអនុវត្តរបបធានារ៉ាប់រងផ្នែកហានិភ័យការងាររបស់ ប.ស.ស រួចមកហើយ តាមរយៈការរៀបចំកិច្ចប្រជុំផ្សព្វផ្សាយ ដែលដឹកនាំដោយលោក អ៊ុក សមវិទ្យា នាយក ប.ស.សនិងលោក ស៊ុំ សោភ័ណ នាយករងប.ស.ស ។ រាជ ធានី-ខេត្តទាំងនោះរួមមាន ៖ រាជធានីភ្នំពេញ ខេត្ត ស្វាយរៀង កំពង់ឆ្នាំង បន្ទាយមានជ័យ ខេត្តសៀមរាប ខេត្តព្រះសីហនុ ខេត្ត កំពង់ចាម ខេត្តក្រចេះ ខេត្តព្រៃវែង ខេត្តតាកែវ ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ។

យោងតាមរបាយការណ៍នៃការប្រជុំផ្សព្វផ្សាយនៅតាមបណ្តារាជធានី-ខេត្តរបស់ថ្នាក់ដឹកនាំ ប.ស.ស កន្លងទៅបានបញ្ជាក់ថា បទបង្ហាញស្តីពីលក្ខណៈទូទៅនៃប្រព័ន្ធសន្តិសុខសង្គមបទបង្ហាញស្តី ពីនិតិវិធីចុះបញ្ជិកា ការបង់ភាគទាន និងការផ្តល់តាវកាលិកនៃការអនុវត្តន៍គោលនយោបាយធានារ៉ាប់រងហានិភ័យការងារត្រូវបានលើកឡើងដោយលោកនាយកនិងលោកនាយករង ប.ស.ស យ៉ាងល្អិតល្អន់ព្រមទាំងផ្តល់ឱកាសឱ្យអ្នកចូលរួម និងភាគីពាក់ព័ន្ធទាំងអស់លើកជាសំណួរដេញដោលបំបាត់ចម្ងល់ថែមទៀតផង។ ជាមួយគ្នានោះដែរតំណាងអាជ្ញាធរដែនដីថ្នាក់រាជធានី និងថ្នាក់ខេត្តទាំងនោះសុទ្ធតែបានទទួលស្គាល់ និងគាំទ្រដល់ការប្រកាសរបស់ ប.ស.ស។

ជុំវិញបញ្ហានេះលោកម៉េង ស៊ុន អភិបាលរងខេត្ត តំណាងឱ្យឯកឧត្តមអភិបាលខេត្តកំពង់ចាម បានអបអរ និងគាំទ្រការដាក់ឱ្យអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារនៅក្នុងខេត្តកំពង់ចាម ដែលធ្វើឱ្យកម្មករនិយោជិតមានទំនុកចិត្តដោយត្រូវបានធានាជួយសង្គ្រោះពីសំណាក់ស្ថាប័ន ប.ស.ស ពេលពួកគេជួបប្រទះគ្រោះដោយគ្រោះថ្នាក់ការងារនោះ។ ក្នុងនាមអាជ្ញាធរខេត្ត លោកអភិបាលរងបានអំពាវនាវឱ្យនាយកឬ ម្ចាស់រោងចក្រ សហគ្រាស គ្រឹះស្ថាន ដែលមានកម្មករនិយោជិតចាប់ពី០៨នាក់ ឡើងទៅមកចុះបញ្ជិកា និងបង់ភាគទានតាមនិតិវិធីក្នុង ប.ស.ស។

ចំណែកលោក សរ ចំរ៉ុង អភិបាលរងខេត្ត ក្រចេះ ក្នុងនាមតំណាងឱ្យឯកឧត្តមអភិបាល និងអាជ្ញាធរខេត្ត ក្រៅពីគាំទ្រ និងអំពាវនាវឱ្យភាគីដែលពាក់ព័ន្ធទាំងអស់ចូលរួមអនុវត្តនោះលោកថែមទាំងទទួលស្គាល់ថា"នេះជាកាតព្វកិច្ចដែលមានចែងក្នុងច្បាប់ ហើយវាក៏ជាយន្តការសម្របសម្រួលរវាងនិយោជក និងកម្មករនិយោ-ជិតពេលដែលកម្មករនិយោជិតទទួលរងគ្រោះថ្នាក់ការងារ"។

តទៅទំព័រ ១១



*តំណាងមកពីគ្រប់ភាគីពាក់ព័ន្ធចូលរួម*

## វែស្វងយល់ពីនីតិវិធីនិងច្បាប់

# ការចុះបញ្ជិកាសហគ្រាសគ្រឹះស្ថាននៅ ប.ស.សគឺជាកាតព្វកិច្ចរបស់និយោជក

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ដែលស្ថិតនៅក្នុងដែនអនុវត្តនៃច្បាប់ស្តីពីរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ត្រូវមានកាតព្វកិច្ចមកចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន របស់ខ្លួននៅបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)។



តំណាងនិយោជកមកចុះបញ្ជិកា និងបង់ភាគទាន

តើសហគ្រាស គ្រឹះស្ថានបែបណាដែលស្ថិត នៅក្នុងដែនអនុវត្តនៃច្បាប់ស្តីពីរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយណាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ?

គឺសម្រាប់វិស័យឯកជន ចំពោះតែសហគ្រាស គ្រឹះស្ថាន ដែលបាននិងកំពុងប្រើប្រាស់កម្មករនិយោជិតចាប់ពី០៨នាក់ឡើងទៅ។



តំណាងនិយោជកមកចុះបញ្ជិកា និងបង់ភាគទាន

-ចំពោះសហគ្រាស គ្រឹះស្ថាន ដែលកំពង់ដំណើរការ ត្រូវមកចុះបញ្ជិកាក្នុងរយៈពេលយ៉ាងយូរ ៤៥ថ្ងៃ (សែសិបប្រាំថ្ងៃ) បន្ទាប់ពីប្រកាសចូលជាធរមាន(ថ្ងៃទី០១ ខែមីនា ឆ្នាំ២០០៨)។

-ចំពោះសហគ្រាស គ្រឹះស្ថាន ដែលបើកដំណើរការក្រោយកាលបរិច្ឆេទចូលជាធរមាននៃប្រកាស ត្រូវមកចុះបញ្ជិកាក្នុងរយៈពេលយ៉ាងយូរ ៤៥ថ្ងៃ(សែសិបប្រាំថ្ងៃ)បន្ទាប់ពីកាលបរិច្ឆេទនៃការចាប់ផ្តើមបើកសហគ្រាស គ្រឹះស្ថានជាស្ថាពរ។

-និយោជក ឬម្ចាស់សហគ្រាសត្រូវផ្ញើបញ្ជីឈ្មោះកម្មករនិយោជិតនៅក្នុងសហគ្រាសរបស់ខ្លួនមក ប.ស.ស ដើម្បីចុះបញ្ជិកាក្នុង ប.ស.ស ។

-ការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន ត្រូវធ្វើតាមទម្រង់ "បញ្ជិកាសហគ្រាស គ្រឹះស្ថាន" ឬហៅថាទម្រង់ "១.០១" ដែលមានចែងក្នុងឧបសម្ព័ន្ធ១ នៃប្រកាសលេខ ០២១,០៨ កប.ប្រក ចុះថ្ងៃទី១១ ខែ កុម្ភៈ ឆ្នាំ២០០៨ ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុង ប.ស.ស ។

-និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវផ្ញើ ភ្ជាប់មកជាមួយនឹងទម្រង់ "១.០១" នូវឯកសារថតចម្លងរួមមាន ៖ វិញ្ញាបនប្រតបញ្ជាក់ការចុះឈ្មោះ ក្នុងបញ្ជីពាណិជ្ជកម្ម ឬលិខិតតួបករណ៍គតិយុត្តសមមូលដទៃទៀត ព្រមទាំងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន។

-ការចុះបញ្ជិកាកម្មករនិយោជិតត្រូវធ្វើតាមទម្រង់"បញ្ជិកាកម្មករនិយោជិត" ឬហៅថាទម្រង់ "១.០២" ដែលមានចែងក្នុងឧបសម្ពន្ធ័២នៃប្រកាសនេះ។ ទម្រង់បញ្ជិកាកម្មករនិយោជិតដែលត្រូវផ្ញើជូន ប.ស.ស អាចធ្វើតាម"ទម្រង់ក្រដាស" ឬ"ទម្រង់អេឡិកត្រូនិក"ដោយមានលិខិតបញ្ជូនដែលចុះហត្ថលេខានាយក ឬម្ចាស់សហគ្រាស

តទៅទំព័រ ១៩

# អត្រាកំណត់ភាគទាននិងបែបបទ
## នៃការបង់ភាគទានសម្រាប់ផ្នែកហានិភ័យការងារ



**កាតព្វកិច្ចនៃការបង់ភាគទាន ៖**

និយោជក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ដែលស្ថិតនៅក្រោមច្បាប់ស្តីពីរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោម បទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារបានចុះបញ្ជិកាក្នុង ប.ស.ស និងមានកម្មករនិយោជិតចាប់ពី ០៨នាក់ (ប្រាំបី)ឡើងទៅត្រូវមានកាតព្វកិច្ចបង់ភាគទានហានិភ័យការងារជូនដល់ ប.ស.ស។ ភាគទានផ្នែកហានិភ័យការងារ គឺជាកាតព្វកិច្ចដោយឡែករបស់និយោជក ឬម្ចាស់សហគ្រាសគ្រឹះស្ថាន។ កម្មករនិយោជិតមិនតម្រូវឱ្យមានកាតព្វកិច្ចក្នុងការបង់ភាគទានផ្នែកនេះឡើយ។

**អត្រាភាគទានហានិភ័យការងារ ៖**

អត្រាភាគទានផ្នែកហានិភ័យការងារជាអត្រាឯកភាពដែលត្រូវបានកំណត់ស្មើ នឹង ០.៨ ភាគរយ (សូន្យក្បៀសប្រាំបី) នៃប្រាក់ឈ្នួលមធ្យមក្នុងលំដាប់ថ្នាក់នៃប្រាក់ឈ្នួលប្រចាំខែ(ប្រាក់ឈ្នួលសរុបដូចមានចែងក្នុងច្បាប់ស្តីពីការងារ) របស់កម្មករនិយោជិត។ ក្នុងករណីដែលសហគ្រាស គ្រឹះស្ថានបើកប្រាក់ឈ្នួលជារូបិយប័ណ្ណបរទេសអត្រានៃប្រាក់ឈ្នួលមធ្យមខាងលើត្រូវទូទាត់តាមអត្រាប្តូរប្រាក់របស់ធនាគាជាតិនៃកម្ពុជា។

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ត្រូវបង់ភាគទានជាប្រចាំខែ។ ការគណនាប្រាក់ភាគទានត្រូវគិតនៅថ្ងៃចុងក្រោយនៃខែដែលត្រូវបង់នីមួយៗ។

**កាលបរិច្ឆេទនៃការបង់ភាគទាន ៖**

កាលបរិច្ឆេទនៃការចាប់ផ្តើមបង់ភាគទានដំបូង ត្រូវបានកំណត់ក្នុងអំឡុងពេល ៣០ថ្ងៃ (សាមសិប) បន្ទាប់ពីកាលបរិច្ឆេទដែល ប.ស.ស បានចេញ "វិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថាន"។ និយោជក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវបង់ភាគទាន សម្រាប់ខែនីមួយៗ យ៉ាងយូរបំផុតនៅថ្ងៃទី១៥ នៃខែបន្ទាប់។ និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ដែលខកខានមិនបានបង់ភាគទាន តាមកាលបរិច្ឆេទខាងលើត្រូវបង់បន្ថែមនូវការប្រាក់តាមចំនួនជាក់ស្តែង និងត្រូវទទួលការពិន័យជាប្រាក់តាមអត្រាអប្បបរមា ដូចមានចែងក្នុងមាត្រាទី ៣៦ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការងារ។



**បែបបទនៃការបង់ភាគទាន ៖**

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានត្រូវបង់ភាគទានដោយផ្ទាល់ចូលទៅក្នុងគណនីរបស់ ប.ស.ស នៅតាមធនាគារដែលបានកំណត់(ធនាគារអេស៊ីលីដា)។ និយោជកឬម្ចាស់សហគ្រាស គ្រឹះស្ថានត្រូវផ្ញើ "បង្កាន់ដៃបង់ភាគទាន" ដែលចេញដោយ ធនាគារមក ប.ស.ស បន្ទាប់ពីថ្ងៃដែលខ្លួនបានបង់។ "បង្កាន់ដៃបង់ភាគទាន "ត្រូវមានចុះលេខអត្តសញ្ញាណសហគ្រាស គ្រឹះស្ថាន និងកាលបរិច្ឆេទនៃការបង់ភាគទាន។

បន្ទាប់ពីបានទទួលបង្កាន់ដៃបង់ភាគទាន ប.ស.ស នឹងចេញលិខិតបញ្ជាក់អំពីការទទួលប្រាក់ភាគទានជូនទៅសហគ្រាសគ្រឹះស្ថានសាម៉ីវិញ។ ក្នុងករណីដែលពិនិត្យឃើញថាភាគទានដែលបានបង់មិនគ្រប់ចំនួន ប.ស.ស ត្រូវកំណត់ឱ្យសហគ្រាសគ្រឹះស្ថានបង់បង្គ្រប់តាមជាក់ស្តែង៕

តមកពីទំព័រ ៨

## រាជធានី-ខេត្តមួយចំនួនត្រូចបាន....

ជាងនេះទៅទៀត ឯកឧត្តម កាន់ វឌ្ឍី អភិបាលរងខេត្តតាកែវ និងឯកឧត្តម ម៉ុក ធារី



អភិបាលរងខេត្តព្រៃវែងដែលតំណាងឱ្យអភិបាល ខេត្តរៀងៗខ្លួននាឱកាសចូលរួមកិច្ចប្រជុំផ្សព្វផ្សាយ របស់ ប.ស.ស ក្នុងនាមអាជ្ញាធរដែនដី ឯកឧត្តមមិនត្រឹមតែបានគាំទ្រ អំពាវនាវឱ្យចូលរួម និងចាត់ទុកជាកាតព្វកិច្ចរបស់ភាគីដែលពាក់ព័ន្ធប៉ុណ្ណោះទេ ជាងនេះទៅទៀតនោះ លោកថែមទាំងសំណូមពរឱ្យគ្រប់ ភាគីពាក់ព័ន្ធទាំងអស់យកចិត្តទុកដាក់អនុវត្តឱ្យបានត្រឹមត្រូវទាន់ពេលវេលាតាមនីតិវិធីនិងបទប្បញ្ញត្តិនានាដែលបានចែងរួចមកហើយនោះទៀតផង ជាពិសេស លោកក៏បានសំណូមពរដល់ស្ថាប័ន ប.ស.ស ឱ្យយកចិត្តទុកដាក់អនុវត្តគោលនយោបាយធានារ៉ាប់រងហានិភ័យការងារនេះប្រកបដោយប្រសិទ្ធភាព និងមានតម្លាភាព។

សូមបញ្ជាក់ថា នៅក្នុងខ្លឹមសារផ្សព្វផ្សាយរបស់ ប.ស.ស បានកំណត់ច្បាស់ថាគ្រឹះស្ថានទាំងអស់ដែលមានប្រើបុគ្គលិកចាប់ពី០៨នាក់ឡើងទៅត្រូវមានកាតព្វកិច្ចមកចុះបញ្ជិកាសហគ្រាសគ្រឹះស្ថាន និងបង់ភាគទានផ្នែកហានិភ័យ



ការងារសម្រាប់កម្មករនិយោជិតរបស់ខ្លួននៅ ប.ស.ស ដែលការបង់ភាគទាននេះជាកាតព្វកិច្ចដោយឡែករបស់និយោជកឬម្ចាស់សហគ្រាសគ្រឹះស្ថានដោយមិនតម្រូវឱ្យកាត់ប្រាក់ឈ្នួលពីកម្មករនិយោ-ជិតនោះទេ។

អត្រាភាគទានផ្នែកហានិភ័យការងារស្មើនឹង ០,៨ភាគរយនៃប្រាក់ឈ្នួលមធ្យមក្នុងលំដាប់នៃប្រាក់ឈ្នួលប្រចាំខែរបស់កម្មករនិយោជិត។

ចំពោះគាវកាលិក ឬ អត្ថប្រយោជន៍ដែលកម្មករនិយោជិតត្រូវទទួលបានពី ប.ស.ស រួមមាន ៖

ការព្យាបាលដោយឥតគិតថ្លៃការទទួលបានប្រាក់បំណាច់ប្រចាំខែការទទួលបានប្រាក់វិភាជន៍ និងធនលាភការផ្តល់ប្រាក់បូជាសព និងធនលាភឧត្តរជីវី ( សម្រាប់អ្នកនៅក្នុងបន្ទុកនៃជនរងគ្រោះ )និងអត្ថប្រយោជន៍ផ្សេងៗមួយចំនួនទៀត។ បើសិនជាជនរងគ្រោះធ្ងន់ធ្ងរហួតដល់ស្លាប់ អ្នកនៅក្នុងបន្ទុករបស់គាត់ដូចជាប្រពន្ធ ឬប្តីគាត់ចាំបាច់ត្រូវមានសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ និងកូនត្រូវមានសំបុត្របញ្ជាក់កំណើត បើមិនដូច្នោះទេពួកគាត់នឹងមិនទទួលបានធនលាភសម្រាប់អ្នកនៅក្នុងបន្ទុកឡើយ។ នៅមានទៀត ប.ស.ស ធ្វើការធានារ៉ាប់រងផ្នែកហានិភ័យការងារធានារ៉ាប់រងផ្នែកសុខភាព ជរាភាព និងរបបធានារ៉ាប់រងផ្សេងៗទៀតនៅក្នុងវិស័យឯកជនស្របតាមស្ថានភាពសង្គម និងសេដ្ឋកិច្ចជាក់ស្តែង របស់ប្រទេសជាតិ។ បច្ចុប្បន្ន ប.ស.ស បានចាប់ផ្តើមអនុវត្តជំហានទី១គឺរបបធានារ៉ាប់ហានិភ័យការងារ។ គ្រោះថ្នាក់និងហានិភ័យការងាររួមមាន ៖

- គ្រោះថ្នាក់ក្នុងអំឡុងពេលបំពេញការងារ គ្រោះថ្នាក់ពេលធ្វើដំណើរពីលំនៅដ្ឋានត្រង់ឆ្ពោះទៅកន្លែងធ្វើការនិងវិលត្រឡប់មកវិញព្រមទាំងជម្ងឺវិជ្ជាជីវៈ។



# អំពីតាវកាលិកហានិភ័យការងារ



**សិទ្ធិទទួលបានតាវកាលិកហានិភ័យការងារ** ៖ កម្មករនិយោជិតទាំងអស់នៃសហគ្រាសគ្រឹះស្ថានដែលបានចុះបញ្ជិកាក្នុង ប.ស.ស មានសិទ្ធិ ទទួលបានតាវកាលិកហានិភ័យការងារនៅពេលដែល សាមីជនទទួលរងហានិភ័យការងារ។ គ្រោះថ្នាក់ការងាររួមមាន ៖ គ្រោះថ្នាក់នៅកន្លែងធ្វើការ គ្រោះ ថ្នាក់នៅពេលធ្វើដំណើរដោយត្រង់ទៅកន្លែងធ្វើការ ឬមកពីកន្លែងធ្វើការ ឆ្ពោះទៅលំនៅដ្ឋាន ការងារដែលនិយោជកតម្រូវអោយទៅនិងជម្ងឺវិជ្ជា ជីវៈ។

**ការជូនដំណឹងហានិភ័យការងារ** ៖ កម្មករនិយោជិតដែលជាសមាជិក ប.ស.ស ត្រូវជូនដំណឹងជាបន្ទាន់ទៅនិយោជក ឬអ្នកតំណាង និយោជកអំពីហានិភ័យការងារ( គ្រោះថ្នាក់ការងារ គ្រោះថ្នាក់ពេលធ្វើដំណើរ និងជម្ងឺវិជ្ជាជីវៈ ) ដែលធ្លាក់មកលើខ្លួន។ ក្នុងករណីដែលមានគ្រោះថ្នាក់ បណ្តាលឱ្យបាត់បង់ជីវិត កាតព្វកិច្ចនៃការជូនដំណឹងនេះ ត្រូវធ្លាក់លើសិទ្ធិវន្តនៃជនរងគ្រោះ។

បន្ទាប់ពីបានទទួលដំណឹងពីកម្មករនិយោជិត ដែលជាអ្នករងហានិភ័យការងារ ឬតំណាងជនរងគ្រោះ និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ ដែលស្ថិតនៅក្នុងដែនអនុវត្តនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅ ក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដែលមានចុះ បញ្ជីកានៅក្នុង ប.ស.ស ត្រូវជូនដំណឹងអំពីឧបទ្ទវហេតុនោះទៅ ប.ស.ស ក្នុងរយៈពេលយ៉ាងយូរបំផុត ៤៨ម៉ោង( សែសិបប្រាំបី ) នៃថ្ងៃធ្វើការ។

**ការផ្តល់សេវាសង្គ្រោះបន្ទាន់** ៖ ក្នុងករណីដែលគ្រោះថ្នាក់កើតឡើងធ្ងន់ធ្ងរដែលតម្រូវឱ្យមានការសង្គ្រោះបន្ទាន់និយោជិត ឬជនរង គ្រោះត្រូវទទួលការសង្គ្រោះបន្ទាន់នៅកន្លែងដែលជិតបំផុត និងបន្ទាប់មកត្រូវបញ្ជូនជនរងគ្រោះទៅមន្ទីរពេទ្យ ឬមន្ទីរពេហុព្យាបាលដែលទទួលស្គាល់ដោយ ប.ស.ស។ ការចំណាយលើការសង្គ្រោះបន្ទាន់ និងការបញ្ជូនខាងលើត្រូវស្ថិតនៅក្នុងបន្ទុករបស់ ប.ស.ស ។ ក្នុងករណីដែលគ្រោះថ្នាក់នៅពេលធ្វើដំណើរសាមីជន ឬនិយោជក អាចទាមទារការទូទាត់សងលើការចំណាយសម្រាប់ការសង្គ្រោះនេះពី ប.ស.ស។




**ការផ្តល់សេវាថែទាំនិងព្យាបាល** ៖ ការព្យាបាលចំពោះកម្មករនិយោជិតដែលរងគ្រោះដោយហានិភ័យការងារ ត្រូវតែ



ប្រព្រឹត្តទៅនៅក្នុងមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាល ដែលទទួលស្គាល់ ដោយ ប.ស.ស។ កម្មករនិយោជិត ដែលទទួលរងហានិភ័យការងារ មានសិទ្ធិទទួលបានការពិនិត្យ ព្យាបាល ការសម្រាកព្យាបាលនៅតាមមន្ទីរពេទ្យឬ មន្ទីរពហុព្យាបាលដែលទទួលស្គាល់ដោយ ប.ស.ស ផ្អែកលើកិច្ចព្រមព្រៀងរវាង ប.ស.ស និងមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលសាមី។

ក្នុងករណីដែលគ្រូពេទ្យព្យាបាលតម្រូវឱ្យទិញឱសថ ឬសម្ភារៈ ឧបករណ៍ដែលចាំបាច់សម្រាប់ការថែទាំនិងព្យាបាលដែលពុំមានចែងក្នុងកិច្ចព្រមព្រៀង ប.ស.ស អាចទូទាត់សងទៅជនរងគ្រោះ ឬអ្នកតំណាងវិញបានលុះណាតែមានវេជ្ជបញ្ជា និងវិក្កយបត្រត្រឹមត្រូវ។

**ការផ្តល់តាវកាលិកសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន** ៖ រយៈពេលនៃការបាត់បង់សមត្ថភាពការងារ

តទៅទំព័រ ១៣

តមកពីទំព័រ ១២



**អំពីតាវកាលិកហានិភ័យការងារ....**

បណ្តោះអាសន្ន គឺជារយៈពេលនៃការព្យាបាលមុខរបួស ឬ ជំងឺវិជ្ជាជីវៈនៅក្នុងមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាល និងរយៈពេលនៃការសម្រាកព្យាបាល ក្រោយពេលមុខរបួសជាសះស្បើយតាមវេជ្ជបញ្ជា។

ក្នុងរយៈពេលនៃការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន កម្មករនិយោជិត



ដែលរងគ្រោះដោយហានិភ័យការងារមានសិទ្ធិទទួលបានតាវកាលិកពី ប.ស.ស នូវ ៖

-ប្រាក់បំណាច់ប្រចាំថ្ងៃដែលត្រូវផ្តល់ជូនគិតចាប់ពីថ្ងៃទីពីរ បន្ទាប់ពីកាលបរិច្ឆេទនៃការកើតឧបទ្ទវហេតុបណ្តាលឱ្យទទួលរងហានិភ័យការងារ។ ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្នត្រូវស្មើនឹង ៧០ភាគរយ (ចិតសិប)នៃប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ។ ប្រាក់ឈ្នួលថ្ងៃផ្អាកការងារដំបូងរបស់ជនរងគ្រោះថ្នាក់ការងារត្រូវនៅក្នុងបន្ទុករបស់និយោជក។ ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការ ងារបណ្តោះអាសន្ន ត្រូវផ្តល់ជូនជនរងគ្រោះរហូតដល់មុខរបួសជាសះស្បើយ សិទ្ធិនៃការទាមទារប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ហានិភ័យការងារ ត្រូវអស់សុពលភាពក្នុងរយៈពេល១ឆ្នាំ(មួយ)។

-ប្រាក់ឧបត្ថម្ភសម្រាប់អ្នកថែទាំជនរងគ្រោះក្នុងរយៈពេលសម្រាកព្យាបាលនៅមន្ទីរពេទ្យឬមន្ទីរ ពហុព្យាបាល។ ប្រាក់នេះត្រូវស្មើនឹង៥០ភាគរយ (ហាសិប)នៃប្រាក់បំណាច់ប្រចាំថ្ងៃរបស់ជនរង គ្រោះ។

**.តាវកាលិកសម្រាប់ការបាត់បង់សមត្ថភាពការងារ ជាអចិន្ត្រៃយ៍** ៖ កម្មករនិយោជិតដែលទទួលរងហានិភ័យការងារបណ្តាលឱ្យបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍តិចជាង ២០ភាគរយ(ម្ភៃ) មានសិទ្ធិទទួលបានប្រាក់វិភាជន៍សម្រាប់ការបាត់បង់សមត្ថភាពការងារ។ ប្រាក់វិភាជន៍នេះត្រូវផ្តល់ជូន អ្នក រងគ្រោះតែម្តងគត់។

កម្មករនិយោជិត ដែលទទួលរងហានិភ័យការងារ បណ្តាលឱ្យបាត់បង់សមត្ថភាពការងារចាប់ពី ២០ភាគរយ (ម្ភៃ)ឡើងទៅ មានសិទ្ធិទទួលបានធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍។ ប្រាក់ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ត្រូវចាត់ទុកជាបណ្តោះអាសន្នជានិច្ច។

ប.ស.ស ត្រូវរៀបចំឱ្យមានការពិនិត្យសុខភាព និងសមត្ថភាពការងារអ្នករងគ្រោះឡើងវិញក្នុងរយៈពេល១ឆ្នាំ(មួយ)យ៉ាងយូរ។ ចំពោះសិទ្ធិក្នុងការទាមទារប្រាក់ធនលាភត្រូវអស់ សុពលភាព ត្រឹមរយៈពេល ៥ឆ្នាំ(ប្រាំ)។ ការបើកប្រាក់ធនលាភត្រូវធ្វើប្រចាំត្រីមាស។

**ប្រាក់បន្ថែមសម្រាប់អ្នកចាំថែរក្សាជនរងគ្រោះ** ៖ កម្មករនិយោជិត ដែលទទួលរងហានិភ័យការងារ បណ្តាលឱ្យបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ដែលតម្រូវឱ្យមានអ្នកថែទាំរក្សាមានសិទ្ធិទទួលបានប្រាក់ឧបត្ថម្ភបន្ថែមស្មើរនឹង៥០ភាគរយ(ហាសិប)នៃប្រាក់ធនលាភរបស់ជនរងគ្រោះ។ សិទ្ធិទទួលបាន

តទៅទំព័រ ២១









# សកម្មភាពអនុវត្តការងារ ជាក់ស្តែងរបស់ ប.ស.ស





យោងតាមរបាយការណ៍ផ្លូវការរបស់ ប.ស.ស គិតត្រឹមដើមឆ្នាំ២០១១ បានអះអាងថា ប.ស.ស បានចាប់ផ្តើមអនុវត្តជំហានទី១ គឺរបបធានារ៉ាប់រងហានិភ័យការងារនៅខែវិច្ឆិកា ឆ្នាំ២០០៨ ដោយទទួលបានសហគ្រាសចុះបញ្ជីកាចំនួន ៣២៧សហគ្រាស នៅឆ្នាំ២០០៩បាន ចំនួន៦៥៦សហគ្រាស និងនៅឆ្នាំ២០១០ បានចំនួន ៩២៧សហគ្រាស។ សរុបជារួម ចាប់ពីពេលដំណើរការរហូតមកដល់ឆ្នាំ២០១០ ប.ស ស បានទទួលសហគ្រាស គ្រឹះស្ថាន មកចុះបញ្ជិកាជាសរុបចំនួន ១៩១០សហគ្រាស ដែលមានកម្មករនិយោជិតប្រមាណជិត ៦សែន (៥៩៤.៦៨៦)នាក់ ។

របាយការណ៍ដដែលបានឱ្យដឹងទៀតថា បើប្រៀបធៀបតួលេខក្នុងឆ្នាំ២០១០និងតួលេខក្នុងឆ្នាំ២០០៩ គឺមានការកើនឡើង២៧១សហគ្រាស។ ការកើនឡើងនេះ ដោយសារនៅដើមឆ្នាំ២០១០ បណ្តាសហគ្រាស គ្រឹះស្ថាន បានពង្រីកវិសាលភាពនៅតាម ខេត្តចំនួន០៥ ផ្សេងទៀត និងធ្វើការផ្សព្វផ្សាយបានទូលំទូលាយ។ ក្នុងចំណោមនោះ សហគ្រាស គ្រឹះស្ថាន ដែលបានបង់ភាគទាននៅឆ្នាំ២០១០មានចំនួនសរុប ១៥៦៤សហគ្រាស ដែលមានកម្មករនិយោជិត សរុបចំនួន ៥៣០.៥៩៩ នាក់។ បើប្រៀបធៀបទៅនឹង ឆ្នាំ២០០៩ ដែលសហគ្រាស គ្រឹះស្ថាន បានបង់ភាគទានមានចំនួន ៨៨៤សហគ្រាស និងមានកម្មករនិយោជិតចំនួន ៣៤០.៨៤០នាក់ នោះ ឃើញថាមាន ការកើនឡើង ៦៨០ សហគ្រាស និងមានកម្មករនិយោជិតចំនួន ១៨៩.៧៥៩នាក់។

ការកើនឡើងនៃចំនួនសហគ្រាស គ្រឹះស្ថាន និងចំនួនកម្មករនិយោជិតបានបង់ភាគទាននេះ ដោយសារម្ចាស់សហគ្រាស គ្រឹះស្ថាន មានការចូលរួមអនុវត្តច្បាប់ និងមានការយល់ដឹងកាន់តែទូលំទូលាយពីការអនុវត្តន៍គោលនយោបាយធានារ៉ាប់រងហានិភ័យការងារជាពិសេសពីអត្ថប្រយោជន៍សម្រាប់កម្មករនិយោជិត និងសង្គម។

របាយការណ៍ដដែលបានឱ្យដឹងថែមថាផ្នែកតាវកាលិកនៃ ប.ស.ស ទទួលបានព័ត៌មានហានិភ័យការងារក្នុងឆ្នាំ២០១០ ចំនួន៦.៧៩២ ករណីហើយតាមរយៈលទ្ធផលនៃការអង្កេត មានគ្រោះថ្នាក់ការងារចំនួន៦០៦៨ករណី។ ក្នុងនោះរបួសស្រាលមានចំនួន៥.៦៧៦ករណី របួសធ្ងន់ ៣៥៨ករណី និងស្លាប់៣៤ករណី។ បើប្រៀបធៀបទៅនឹងឆ្នាំ២០០៩ ដែលមានគ្រោះថ្នាក់ការងារចំនួន២.៤២៣ករណី ឃើញថាចំនួនគ្រោះថ្នាក់ការងារមានការកើនឡើង ៣.៦៤៥ ករណី។ ការកើនឡើងនៃចំនួនគ្រោះថ្នាក់ការងារនេះបណ្តាលមកពីមានបញ្ហាដួលសន្លប់នៅក្នុងរោងចក្រខេត្តកំពង់ឆ្នាំង និងនៅរាជធានីភ្នំពេញ ក្នុងឆមាសទី២ ឆ្នាំ២០១០។ ម្យ៉ាងទៀតក៏មកពីមានការកើនឡើងនៃចំនួនសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតដែលបានចុះបញ្ជិកា និងបង់ភាគទាននៅ ប.ស.ស និងកម្មករនិយោជិតមានការយល់ដឹងកាន់តែទូលំទូលាយពីសិទ្ធិ និងតាវកាលិក (អត្ថ-ប្រយោជន៍) ដែលខ្លួនត្រូវទទួលបានតាមច្បាប់។

ទាក់ទងនឹងការសម្រេចផ្តល់តាវ

តទៅទំព័រ ១៦

តមកពីទំព័រ ៦

## តួនាទីនិងសមត្ថកិច្ចរបស់បេឡា...

សុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដែលធ្វើការងារលើផ្នែកអង្កេតគ្រោះថ្នាក់ការងារ។ ដោយផ្អែកទៅលើស្ថានភាពអភិវឌ្ឍន៍នៃសេដ្ឋកិច្ចជាតិ និងជាការឆ្លើយតបទៅនឹងការរីកចម្រើននៃវិស័យការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានខិតខំប្រឹងប្រែងយ៉ាងមមាញឹកចងក្រងនូវលិខិតតូបករណ៍គតិយុត្តជាច្រើន ដើម្បីឱ្យមានការអនុវត្តន៍ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារឱ្យមានដំណើរការ និងប្រកបដោយប្រសិទ្ធភាព។

ឯកឧត្តម បានរំលើកឡើងថា ចាប់តាំងពីឆ្នាំ ២០០៤ ដល់ឆ្នាំ ២០០៦ សកម្មភាពចម្បងរបស់នាយកដ្ឋាន គឺ



ផ្តោតទៅលើការសិក្សា ស្រាវជ្រាវលទ្ធភាពដំណើរការរបបធានារ៉ាប់រងហានិភ័យការងារ និងការតាក់តែងច្បាប់។ ក្នុងឆ្នាំ ២០០៦ នាយកដ្ឋានព្រមទាំងថ្នាក់ដឹកនាំក្រសួងបានប្រឹងប្រែងគ្រប់លទ្ធភាពដើម្បី រៀបចំឡើងនូវសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម និងបានដាក់សេចក្តីព្រាងនេះទៅក្នុងការប្រជុំពិភាក្សាជាបន្តបន្ទាប់ទាំងផ្ទៃក្នុងនាយកដ្ឋានផ្ទៃក្នុងក្រសួង អន្តរក្រសួង សមាគមនិយោជក សមាគមកម្មករនិយោជិត និងក្រុមប្រឹក្សាអ្នកច្បាប់ នៃទីស្តីការគណៈរដ្ឋមន្ត្រី។ ហើយនៅទីបំផុត កិច្ចខិតខំប្រឹងប្រែងនេះបានសម្រេចលទ្ធផលជាផ្លែផ្កាដោយអនុក្រឹត្យស្តីពីការបង្កើត បេឡាជាតិរបបសន្តិសុខសង្គមតាមរយៈការអនុម័តយល់ព្រមក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនាដើមខែមីនា ឆ្នាំ២០០៧៕

តមកពីទំព័រ ៧

## ក្រុមប្រឹក្សាភិបាល ប.ស.ស ក្នុង...

ប្រកាសស្តីពីការកំណត់តួនាទីភារកិច្ចរបស់អធិការ និងអភិបាលសន្តិសុខសង្គមនៃ ប.ស.ស។

-ប្រកាសស្តីពីសមាសភាព និងការប្រព្រឹត្តទៅរបស់គណៈកម្មការដោះស្រាយវិវាទ ឬបណ្តឹងនៃ ប.ស.ស។

-ប្រកាសស្តីពីការកែសម្រួលប្រការ៧ និងប្រការ៩ នៃប្រកាសលេខ ១០៩ កប.ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ។

-ប្រកាសស្តីពីការតែងតាំងគណៈកម្មការវេជ្ជសាស្ត្រនៃ ប.ស.ស។

ប្រកាសស្តីពីការបង់ភាគទានហានិភ័យការងារនៃសហគ្រាស គ្រឹះស្ថានកាត់ដេរ និងស្បែកជើងសម្រាប់ឆ្នាំ២០០៩-២០១០។

-សេចក្តីសម្រេចស្តីពីបែបបទនៃការប្រគល់សិទ្ធិអំណាចក្នុងការដឹកនាំនិងការទទួលខុសត្រូវរបស់នាយក ប.ស.ស។

-សេចក្តីសម្រេចស្តីពីវិធានសម្រាប់ការប្រជុំក្រុមប្រឹក្សាភិបាលរបស់ ប.ស.ស។

-សេចក្តីសម្រេចស្តីពីបទបញ្ជាផ្ទៃក្នុងនៃ ប.ស.ស។

-សេចក្តីសម្រេចស្តីពីបញ្ជីឈ្មោះមន្ទីរពេទ្យ ឬមន្ទីរព្យាបាលទទួលស្គាល់ដោយ ប.ស.ស។

-សេចក្តីសម្រេចស្តីពីលក្ខន្តិកៈបុគ្គលិក ប.ស.ស -សេចក្តីសម្រេចស្តីពីការកំណត់តំលៃឯកតា នៃសន្ទស្សន៍ និងប្រាក់វិភាជន៍គ្រួសារសម្រាប់បុគ្គលិក ប.ស.ស។

-សេចក្តីសម្រេចស្តីពីការដាក់ប្រើប្លង់គណនេយ្យរបស់ ប.ស.ស។

-សេចក្តីសម្រេចស្តីពីថវិកាប្រចាំឆ្នាំ ២០០៩ របស់ ប.ស.ស។

-សេចក្តីសម្រេចស្តីពីការកំណត់លាភការមុខងារសមាជិកគណៈកម្មការវេជ្ជសាស្ត្រនៃប.ស.ស។

-សេចក្តីសម្រេចស្តីពីការកំណត់លាភការមុខងារគណៈកម្មការដោះស្រាយវិវាទឬបណ្តឹងនៃ ប.ស.ស

-សេចក្តីសម្រេចស្តីពីនីតិវិធីដោះស្រាយវិវាទ ឬបណ្តឹងនៃ ប.ស.ស។





តមកពីទំព័រ ២១

## សកម្មភាពអនុវត្តការងារជាក់....

កាលិកហានិភ័យការងារ របាយការណ៍ដដែលបានបញ្ជាក់ច្បាស់ថាក្នុងឆ្នាំ២០១០ ប.ស.ស បានចេញសេចក្តីសម្រេចផ្តល់តាវកាលិកហានិភ័យការងារជាច្រើនប្រភេទ ដែលមានចំនួនទឹកប្រាក់សរុប ២.៤២៣.៦០២.៩១១ រៀល។ ក្នុងនោះបានចំណាយច្រើនជាងគេទៅលើតាវកាលិកព្យាបាល អស់ចំនួន ១.៩៣៧.៧៤៧.២១១រៀល តាវកាលិកបាត់បង់សមត្ថភាពការងារបណ្តោះអាសន្នចំនួន ៣៥៦.២៣៥.១០០ រៀលនិងតាវកាលិក ផ្សេងទៀតសរុបចំនួន ១២៥.៦២០.៦០០រៀល។

ដោយឡែកកាលពីឆ្នាំ២០០៩ការចំណាយទៅលើតាវកាលិកហានិភ័យ



ការងារច្រើនប្រភេទមានចំនួន ១.០៧៦.០៧១.៦០០រៀល។ ក្នុងនោះបានចំណាយច្រើនជាងគេទៅលើតាវកាលិកព្យាបាល និងតាវកាលិកបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន។ បើធ្វើការប្រៀបធៀបឃើញថាការចំណាយតាវកាលិកហានិភ័យការងារក្នុងឆ្នាំ២០១០ មានការកើនឡើងជាងការចំណាយនៅឆ្នាំ២០០៩ ប្រមាណជា ១.៣៤៧.៥៣១.៣១១រៀល។

ទាក់ទងនឹងរបាយការណ៍នេះដែរ លោកនាយក ប.ស.ស បានទទួលស្គាល់ថាមានជួបបញ្ហាមួយចំនួនលើការអនុវត្តន៍ជំហានទី១ ទាក់ទងនឹងនិយោជកនិងកម្មករនិយោជិត ដោយសហគ្រាស គ្រឹះស្ថានមួយចំនួនរាយការណ៍ពីចំនួនសាខាកម្មករនិយោជិត និងប្រាក់បៀវត្សរ៍ មិនគ្រប់តាមចំនួនជាក់ស្តែង និងមានការយឺតយូរក្នុងការផ្តល់របាយការណ៍ហានិភ័យការងារដែលកត្តាទាំងនេះបានធ្វើឱ្យបាត់បង់ដល់អត្ថប្រយោជន៍កម្មករនិយោជិតនាំឱ្យការផ្តល់តាវកាលិកមានការយឺតយ៉ាវ។

លោកនាយកបាន លើកឡើងទៀតថា ចំពោះកម្មករនិយោជិតវិញមួយចំនួនមិនមានឯកសារបញ្ជាក់ពីអត្តសញ្ញាណរបស់ខ្លួន (ខ្ចីឯកសារអ្នកដទៃមកប្រើ) ប្រើប្រាស់សេវាមិនចំគោលដៅជាហេតុនាំឱ្យមានភាពមិនច្បាស់លាស់ក្នុងការផ្ទៀងផ្ទាត់ឯកសារផ្លូវច្បាប់ក្នុងការសម្រេចផ្តល់តាវកាលិកឱ្យបានត្រឹមត្រូវ និងកម្មករនិយោជិត មួយចំនួនទៀត ដែលបានរៀបអាពាហ៍ពិពាហ៍ហើយតែមិនមានសំបុត្រអាពាហ៍ពិពាហ៍នាំឱ្យសមាជិកក្នុងបន្ទុកគ្រួសាររបស់គាត់មិនអាចទទួលបានតាវកាលិកឧត្តរជីវីនៅពេលរងគ្រោះថ្នាក់ការងាររហូតដល់មានការបាត់បង់ជីវិត។

លោកនាយកបាន ធ្វើការកត់សម្គាល់ឃើញថាក្នុងចំណោមគ្រោះថ្នាក់ការងារទាំងអស់ករណីដួលសន្លប់នៅកន្លែងធ្វើការមានចំនួនច្រើនជាងគេគួរឱ្យព្រួយបារម្ភ និងបន្ទាប់មកមានគ្រោះថ្នាក់ការងារទាក់ទងនឹងការធ្វើដំណើរ គឺជាចំនួនមួយដែលត្រូវយកចិត្តទុកដាក់ខ្ពស់ផងដែរក្នុងនោះភាគច្រើនជាគ្រោះថ្នាក់ចរាចរដែលសុទ្ធតែជាគ្រោះថ្នាក់ធ្ងន់ធ្ងរ និងជាយថាហេតុបណ្តាលឱ្យបាត់បង់ជីវិតទៀតផង។ លោកនាយកបានបញ្ចេញទស្សនៈផ្ទាល់ខ្លួនថាបញ្ហានេះទាមទារឱ្យមានការចូលរួមយ៉ាងសកម្ម និងមិនអាចពន្យារពេលបានពីសំណាក់ក្រសួង អង្គការជាតិ-អន្តរជាតិ សហគមន៍ និងស្ថាប័នពាក់ពន្ធ័នានា ក្នុងការចាត់វិធានការអប់រំ ផ្សព្វផ្សាយដើម្បីបង្ការ និងទប់ស្កាត់កម្រិតគ្រោះថ្នាក់ការងារជាពិសេសគ្រោះថ្នាក់ចរាចរឱ្យនៅទាបបំផុតដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ស្ថេរភាពសង្គមនៅកម្ពុជា។ ម្យ៉ាងទៀតកម្មករនិយោជិតខ្លួនឯងផ្ទាល់ត្រូវមានការយល់ដឹង និងប្រុងប្រយ័ត្នខ្ពស់នៅក្នុងការបំពេញការងារ ជាពិសេសការធ្វើដំណើរទៅមកដើម្បីជៀសវាងកុំឱ្យមានគ្រោះថ្នាក់ព្រោះវានាំឱ្យខាតបង់ការងារពេលវេលាថវិកា និងអាយុជីវិតផងដែរ។



# កិច្ចព្រមព្រៀងនិងអនុស្សរណៈ

## នៃការយោគយល់គ្នា រវាង ប.ស.ស និងដៃគូពាក់ព័ន្ធនានាដែលបានធ្វើឡើងកន្លងមកអំពីកិច្ចប្រតិបត្តិការជាមួយដៃគូពាក់ព័ន្ធនានា

ចាប់តាំងពីឆ្នាំ ២០០៨ មកម្ល៉ះ ដោយមានការអនុញ្ញាតពីក្រសួងអាណាព្យាបាលទាំង២ គឺក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈបេឡាជាតិរបបសន្តិសុខសង្គមបានចុះកិច្ចព្រមព្រៀងមួយជាមួយធនាគារអេស៊ីលីដាស្តីពី"ការប្រើប្រាស់សេវាធនាគារនិងបើកគណនី" ។

តាមការអះអាងរបស់លោកនាយក ប.ស.ស កន្លងទៅបានបញ្ជាក់យ៉ាងច្បាស់ថាចាប់តាំងពីពេលនោះមកគ្រប់ប្រតិបត្តិការផ្នែកហិរញ្ញវត្ថុរបស់ ប.ស.ស សុទ្ធតែត្រូវបានឆ្លុះបញ្ចាំងយ៉ាងច្បាស់លាស់នៅក្នុងរបាយការណ៍ធនាគារ។

លោកនាយបានឱ្យដឹងថាចំពោះរាល់ការចំណាយផ្សេងៗ និងការបើកប្រាក់ឧបត្ថម្ភរបស់មន្ត្រី ប.ស.ស ត្រូវបានឆ្លងកាត់តាមប្រព័ន្ធធនាគារទាំងស្រុង។




ចំណែក នៅក្នុងដំណើរការនៃការប្រមូលប្រាក់ភាគទាន ប.ស.ស បានតម្រូវឱ្យនិយោជកទៅបង់ផ្ទាល់នៅធនាគារ។ ហើយការផ្តល់គាំកាលិក រួមទាំងការទូទាត់ថ្លៃព្យាបាលផង ក៏ត្រូវបានធ្វើឡើងតាមប្រព័ន្ធធនាគារដូចគ្នា។

លោកនាយក ប.ស.ស បានថ្លែងថា ការអនុវត្តន៍ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុតាមរយៈធនាគារបែបនេះ ម្យ៉ាងអាចជួយសម្រួល និងសន្សំសំចៃពេលវេលារបស់និយោជក និងម្យ៉ាងទៀតជួយឱ្យបងប្អូន





កម្មករនិយោជិតដែលពិការដោយការងារ ឬមានទីលំនៅនៅតំបន់ដាច់ស្រយាល អាចបើកប្រាក់ឧបត្ថម្ភរបស់ខ្លួននៅតាមសាខាធនាគារអេស៊ីលីដា ដែលនៅជិតផ្ទះដោយមិនចាំបាច់ធ្វើដំណើរឆ្ងាយមកបើកនៅ ទីរួមខេត្តឬនៅភ្នំពេញនោះទេ។

លោកនាយកបានចាត់ទុកថា ជារួមការគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធធនាគារអាចធានាបាននូវប្រសិទ្ធភាពនិងតម្លាភាពនៅក្នុងការគ្រប់គ្រងចំណូល និងចំណាយដែលវាស្របទៅនឹងស្ថានភាពរីកចម្រើនរបស់ប្រទេស និងតម្រូវការរបស់អតិថិជនជាសំខាន់ទៀតផង។

ដោយឡែកជាបន្តបន្ទាប់នៅចុងឆ្នាំ ២០១០ អនុស្សរណៈនៃការយោគយល់គ្នារវាង "ប.ស.ស" និង "សេវាកម្មសុខុមាលភាពនិងការជួសជុលគ្រោះថ្នាក់ការងារ" នៃសាធារណរដ្ឋកូរ៉េ ក៏ត្រូវបានធ្វើឡើងផងដែរដោយមានខ្លឹមសារផ្តោតជាសំខាន់ទៅលើការអភិវឌ្ឍន៍សមត្ថភាពជាដៃគូរវាង ប.ស.ស នៃក្រសួងការងារនិង បណ្តុះបណ្តាលវិជ្ជាជីវៈកម្ពុជា និងសេ-វាកម្មសុខុមាលភាពនិងការជួសជុលគ្រោះថ្នាក់ការងារកូរ៉េព្រមទាំងជំរុញឱ្យមានការផ្លាស់ប្តូរបទពិសោធន៍ការងារ ការបណ្តុះបណ្តាលធនធានមនុស្សទស្សនៈកិច្ចសិក្សា និងអ្នកជំនាញការសម្រាប់ផ្នែកធានារ៉ាប់រងហានិភ័យការងារនៃភាគីទាំងពីរ។




ទាក់ទងទៅនឹងផ្លែផ្កានៃកិច្ចព្រមព្រៀង និង អនុស្សរណៈដែល ប.ស.ស បានធ្វើឡើងជាមួយដៃគូពាក់ព័ន្ធកន្លងទៅនោះថ្នាក់ដឹកនាំ ប.ស.សបានឱ្យដឹងថាមានមន្ត្រី ប.ស.ស មួយចំនួនត្រូវបានចាត់បញ្ជូនឱ្យទៅធ្វើទស្សនៈកិច្ចសិក្សានៅសាធារណរដ្ឋកូរ៉េ សាធារណរដ្ឋសង្គមនិយមវៀតណាម និងនៅប្រទេសអាល្លឺម៉ង់ផងដែរ។



មន្ត្រីផ្លូវការរបស់ ប.ស.ស បានបញ្ជាក់ថែមថាដំណើរទស្សនកិច្ចទាំងអស់កន្លងទៅសុទ្ធតែមានការអញ្ជើញជាផ្លូវការពីសំណាក់ដូចជា -អង្គការពលកម្មអន្តរជាតិខាងការងារដែលហៅកាត់ថា (ILO) -ការិយាល័យសុខភាពរបស់ INWENT នៃរដ្ឋាភិបាលអាល្លឺម៉ង់ -ក្រសួងសុខាភិបាលអង្គការសហប្រតិបត្តិការរបស់អាល្លឺម៉ង់...។ល។

ប្រភពព័ត៌មានពី ប.ស.ស ក៏បានឱ្យដឹងទៀតថាខ្លឹមសារនៃដំណើរទស្សនៈកិច្ចសិក្សាទាំងនោះរួមមាន ទៅចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលស្តីពី "ការធានារ៉ាប់រងសុខភាពសង្គម" ដែលមានបំណងចង្អុលបង្ហាញពីការសិក្សានៅក្នុងតំបន់ជាច្រើនចំពោះបញ្ហាសុខភាព ជុំវិញការបង្កើនសមត្ថភាពឱ្យមានប្រសិទ្ធភាពចំពោះសុខភាព។ មួយវិញទៀតទស្សនៈកិច្ចខ្លះក៏ដើម្បីស្វែងយល់ពីប្រព័ន្ធហិរញ្ញប្បទានសុខាភិបាល និងសិក្សាពីបទពិសោធន៍គ្របដណ្តប់ការថែទាំសុខភាពដល់ប្រជាជនវៀតណាម តាមរយៈការធានារ៉ាប់រងសុខភាពសង្គម។ ជាងនេះទៅទៀតនៅមានទស្សនៈកិច្ចទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការធានារ៉ាប់រងគ្រោះថ្នាក់ការងារ និងការធានារ៉ាប់រងការងារ ដែលគោលដៅនៃការធានារ៉ាប់រងហានិភ័យការងារសង្គម គឺផ្តល់ឱកាសឱ្យជនរងគ្រោះដោយ គ្រោះថ្នាក់ការងារអាចវិលត្រឡប់ទៅធ្វើការវិញប្រកបដោយក្តីសង្ឃឹមបើទោះបីជាគាត់ធ្លាក់ខ្លួនក្នុងស្ថានភាពជាជនពិការក៏ដោយ។

# វេទិកាភាគីពាក់ព័ន្ធ


លោក វ៉ាន់ ស៊ូអៀង ប្រធានសហព័ន្ធ

និយោជកនិងសមាគមពាណិជ្ជកម្មកម្ពុជា ហៅកាត់ថា (CAMFEBA) ធ្លាប់បានទទួល ស្គាល់នៅក្នុងពិធី បូកសរុបការងារ ប.ស.ស សម្រាប់ឆ្នាំ២០០៩ និងទិសដៅអនុវត្តបន្តសម្រាប់ឆ្នាំ២០១០ កាលពីដើមឆ្នាំ ២០១០ កន្លងទៅថាលទ្ធផលការងាររបស់ ប.ស.ស ដែលសម្រេចបានក្នុងឆ្នាំ២០០៩ គឺជាជោគជ័យមួយ បើទោះបីវាមិនមែនជាតួលេខមួយដែលធំ ប៉ុន្តែវាគឺ ជាសញ្ញាវិជ្ជមានមួយបង្ហាញពីការគាំទ្ររបស់វិស័យឯកជន។ ហើយថា ជំនួសមុខឱ្យនិយោជកនៅក្នុងប្រទេសកម្ពុជា លោកសូមកោតសរសើរយ៉ាងខ្លាំងក្លាចំពោះជោគជ័យនេះ។

លោក វ៉ាន់ ស៊ូអៀង ក៏បានលើកឡើងផងដែរថា ដោយសារតែវិស័យឯកជនចង់ឃើញតម្លាភាព និងគណនេយ្យភាពចំពោះការគ្រប់គ្រងបេឡានេះ ហើយដោយបានធ្វើការយ៉ាងជិតស្និទជាមួយនិយោជក និងសមាគមជំនួញនៅក្នុងប្រទេសកម្ពុជាពាក់ព័ន្ធនឹង ប.ស.ស នេះ CAMFEBA បានទទួលនូវអនុសាសន៍ និង ការផ្តល់យោបល់មកវិញជាច្រើនពីសមាជិករបស់ខ្លួនដើម្បីឱ្យ ប.ស.ស អាចយកទៅ ពិចារណាដូចជា ៖

១- ប.ស.ស គប្បីតែងតាំងបុគ្គលិកបន្ថែមឱ្យទទួលទូរសព្ទ័ទាន់ហេតុការណ៍សម្រាប់ករណីរាយការណ៍គ្រោះថ្នាក់ការងារដើម្បីអាចឱ្យអ្នកជំងឺចូលសម្រាកនៅមន្ទីរពេទ្យ និងលិខិតស្នាមផ្សេងៗអាចដំណើរការឡើងក្នុងមធ្យោបាយមួយដែលលឿន។ ២-សេវាសុខាភិបាលដែលផ្តល់ដោយមន្ទីរពេទ្យទទួលស្គាល់ដោយ ប.ស.ស គប្បីធ្វើឱ្យប្រសើរជាងមុនដើម្បីធានាថា និយោជិតរងគ្រោះទាំងអស់ទទួលបានសេវាព្យាបាលទាន់ពេលនិងដោយសមរម្យ ៣-គប្បីមានទម្រង់វេជ្ជបញ្ជាផ្លូវការដែលត្រូវបានបំពេញដោយគ្រូពេទ្យពីព្រោះវាសំខាន់សម្រាប់កម្មករនិយោជិតទាំងឡាយក្នុងការបញ្ជូនទម្រង់ទាមទារមួយដែលពេញលេញ និងច្បាស់លាស់ ៤-គប្បីមានការពិគ្រោះហ្មត់ចត់ជាមួយវិស័យឯកជនមុនពេលមានការអនុម័តច្បាប់និងបទប្បញ្ញត្តិណាមួយដើម្បីធានាថា ច្បាប់ ឬបទបញ្ញត្តិនោះ អាចដំណើរការបាន និងមិនរារាំងលទ្ធភាពប្រកួតប្រជែងរបស់កម្ពុជា។

ចំណែកលោក អាត់ ធន ប្រធានសហភាពការងារ CLC បានផ្តល់អនុសាសន៍ថា ៖

តទៅទំព័រ ៤៧

តមកពីទំព័រ ៩

## រាជធានី-ខេត្តមួយចំនួនត្រូវបាន....

គ្រឹះស្ថាន។

-ប.ស.ស នឹងផ្តល់លេខអត្តសញ្ញាណសម្រាប់សហគ្រាស គ្រឹះស្ថាននីមួយៗ បន្ទាប់ពីទទួលបានទម្រង់ "បញ្ជិកាសហគ្រាស គ្រឹះស្ថាន"។ សហគ្រាស គ្រឹះស្ថានមួយត្រូវទទួលបានលេខអត្តសញ្ញាណតែមួយគត់ដែលឱ្យឈ្មោះថា "អត្តសញ្ញាណសហគ្រាស គ្រឹះស្ថាន"។

-រៀងរាល់ខែ និយោជកដែលជានាយកឬម្ចាស់ សហគ្រាស គ្រឹះស្ថាន ត្រូវផ្ញើរបាយការណ៍អំពីចំនួន កម្មករនិយោជិតមក ប.ស.ស ឱ្យបានមុនថ្ងៃទី១៥ នៃខែ


តំណាងនិយោជកមកចុះបញ្ជិកា និងបង់ភាគទាន

បន្ទាប់។ របាយការណ៍អំពីចំនួនកម្មករនិយោជិតត្រូវធ្វើឡើងដូចគ្នានឹងទម្រង់ "បញ្ជិកាកម្មករនិយោជិត" ដោយត្រូវបញ្ជាក់បន្ថែមអំពីចំនួនកម្មករនិយោជិតទាំងអស់ដែលមាននៅក្នុងខែត្រូវរាយការណ៍។ របាយការណ៍អំពីចំនួនកម្មករនិយោជិតដែលត្រូវផ្ញើជូន ប.ស.ស អាចធ្វើតាម "ទម្រង់ក្រដាស"ឬ"ទម្រង់អេឡិចត្រូនិក" ដោយមានលិខិតបញ្ជូនដែលចុះហត្ថលេខានាយក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន។

តមកពីទំព័រ ១៣

**អំពីធានាគារលិកហានិភ័យការងារ....**

អ្នកចាំថែរក្សា ត្រូវសម្រេចដោយនាយក ប.ស.ស អនុលោមទៅតាមការវាយតម្លៃរបស់គណៈកម្មការវេជ្ជសាស្ត្រ។

**ប្រាក់វិភាជន៍ជាសោហ៊ុយបូជាសព ៖** ក្នុងករណីដែលមានការទទួលរងហានិភ័យការងាររហូតបណ្ដាលឱ្យបាត់បង់ជីវិតអ្នកទទួលរ៉ាប់រងក្នុងការចាត់



ចែងបូជាសពត្រូវបានផ្ដល់ប្រាក់វិភាជន៍ជាសោហ៊ុយបូជាសពដែលមានចំនួន ៤.០០០.០០០រៀល(បួនលាន)។ ប្រាក់វិភាជន៍នេះត្រូវតែផ្ដល់ជូនទៅជនដែលទទួលបន្ទុកផ្ទាល់ក្នុងការចាត់ចែងបូជាសពជនរងគ្រោះ។ សិទ្ធិនៃការទាមទារប្រាក់វិភាជន៍បូជាសព ត្រូវអស់សុពលភាពត្រឹមរយៈពេល១ឆ្នាំ (មួយ)។

**តាវកាលិកឧត្តរជីវី ៖** តាវកាលិកឧត្តរជីវី គឺជាប្រាក់ធនលាភដែលត្រូវផ្ដល់ឱ្យសិទ្ធិវន្តនៃជនរងគ្រោះរួមមានទាំង ប្រពន្ធ ឬប្ដី កូន និងឪពុកម្ដាយ ឬមនុស្សចាស់ជរានៅក្នុងបន្ទុក។

-សិទ្ធិវន្តជាប្រពន្ធ ឬប្ដីនៃជនរងគ្រោះត្រូវមានលិខិតបញ្ជាក់អាពាហ៍ពិពាហ៍។ សិទ្ធិទទួលធនលាភ ចំពោះសិទ្ធិវន្តដែលជាប្រពន្ធ ឬប្ដី ត្រូវបានរំលាយនៅ ពេលដែលសាមីជនរៀបអាពាហ៍ពិពាហ៍ជាថ្មី។

-សិទ្ធិវន្តជាកូន ដែលមានអាយុត្រឹម ១៨ឆ្នាំ (ដប់ប្រាំបី)ចុះដែលមិនទាន់រៀបអាពាហ៍ពិពាហ៍ និងជាកូននៃសហព័ទ្ធដែល



បានរៀបអាពាហ៍ពិពាហ៍ដោយមានចុះបញ្ជីអត្រានុកូលដ្ឋានត្រឹមត្រូវ និងកូនចិញ្ចឹមអនុលោមតាមបទបញ្ញត្តិជាធរមាន។ អាយុកូននៅក្នុងបន្ទុកអាចកំណត់ដល់ ២១ឆ្នាំ (ម្ភៃមួយ)ចំពោះកូនដែលកំពុងទទួលការបណ្ដុះបណ្ដាល។

-ឪពុកម្ដាយ ឬមនុស្សចាស់ជរាដែលស្ថិតនៅក្នុងបន្ទុកផ្ទាល់របស់សមាជិក ប.ស.ស។

សិទ្ធិទទួលធនលាភនៃសិទ្ធិវន្តត្រូវបានរំលាយនៅពេលដែលសាមីជនទទួលមរណភាព។

**សេវាបុនទីតិសម្បទា ៖** កម្មករនិយោជិតដែលរងហានិភ័យការងារបណ្ដាលឱ្យបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍មានសិទ្ធិទទួលបាន ៖

-ឧបករណ៍ ឬអវៈយវៈសិប្បនិម្មិតតាមការកំណត់របស់គ្រូពេទ្យផ្លូវការ ឬគ្រូពេទ្យដែលទទួលស្គាល់ដោយ ប.ស.ស។

-សេវាសម្របសម្រួលមុខងារ និងការបណ្ដុះបណ្ដាលវិជ្ជាជីវៈឡើងវិញ។

**ការទាមទារតាវកាលិក ៖**

-ការទាមទារតាវកាលិកសម្រាប់ការថែទាំ និងព្យាបាល អាចត្រូវបានធ្វើឡើងដោយមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលដែលបានព្យាបាលជនរងគ្រោះ ឬនិយោជក ឬក៏កម្មករនិយោជិតជាជនរងគ្រោះផ្ទាល់ដូចមានចែងក្នុងប្រកាសលេខ ១០៩ ក.ប/ប្រ.ក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្ដីពីតាវកាលិកហានិភ័យការងាររបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ។

**ការយល់ព្រមចំពោះការទាមទារតាវកាលិក ៖** តាវកាលិកថែទាំ និងព្យាបាលដែលត្រូវបានទទួលការយល់ព្រមពី ប.ស.ស លុះណាតែការថែទាំ និងព្យាបាលនោះធ្វើនៅក្នុងមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលដែលទទួលស្គាល់ដោយ ប.ស.ស។

ប្រសិនបើការថែទាំ និងព្យាបាលធ្វើនៅមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលផ្សេងក្រៅពីការកំណត់របស់ ប.ស.ស ការទូទាត់សងវិញត្រូវធ្វើតាមអត្រាតម្លៃដែល ប.ស.ស បានកំណត់៕



## ដើម្បីទទួលបានសេវាព្យាបាលដោយឥតគិតថ្លៃ



- លុះត្រាតែជាគ្រោះថ្នាក់ការងារ
- សម្រាកព្យាបាលនៅមន្ទីរពេទ្យ ដែលបានចុះកិច្ចសន្យាជាមួយ ប.ស.ស
- ក្នុងករណីសង្គ្រោះបន្ទាន់ អាចសង្គ្រោះនៅកន្លែងដែលជិតបាន
- បើមិនព្យាបាលនៅមន្ទីរពេទ្យ ដែលបានចុះកិច្ចសន្យាជាមួយ ប.ស.ស ទោះលក់ការចំណាយលើការព្យាបាល នឹងធ្វើការទូទាត់សងវិញតាមការកំណត់របស់ ប.ស.ស ។

## ដើម្បីទទួលបានប្រាក់ឧបត្ថម្ភផ្សេងៗ

ជនរងគ្រោះ ឬអ្នកតំណាង ត្រូវធ្វើការស្នើសុំតាមទម្រង់តាវកាលិកនីមួយៗ ដូចខាងក្រោម៖

១- តាវកាលិកថែទាំ និងព្យាបាល

- ឯកសារលំអិតអំពីការព្យាបាល
- វិក្ក័យបត្រថ្លៃព្យាបាល ឬការទិញឱសថផ្សេងៗតាមវេជ្ជបញ្ជា

២- តាវកាលិកបាត់បង់សមត្ថភាពការងារបណ្ដោះអាសន្ន

- លិខិតបញ្ជាក់ពីគ្រូពេទ្យ អំពីការសម្រាកព្យាបាល
- លិខិតអនុញ្ញាតច្បាប់ពីសហគ្រាស គ្រឹះស្ថាន

៣- តាវកាលិកបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍

- ឯកសារវាយតម្លៃការបាត់បង់សមត្ថភាពការងារ របស់គណៈកម្មការវេជ្ជសាស្ត្រ ឬគ្រូពេទ្យផ្លូវការ

៤-វិភាជន៍បូជាសព

- សេចក្ដីចម្លងសំបុត្រមរណៈភាព

៥- តាវកាលិកឧត្តរជីវី

- ចំពោះប្រពន្ធ ឬប្ដីត្រូវមានសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍

***បញ្ជាក់៖*** ដើម្បីទទួលបានប្រាក់ឧបត្ថម្ភខាងលើ ជនរងគ្រោះ ឬអ្នកតំណាងត្រូវភ្ជាប់មកជាមួយនូវ អត្តសញ្ញាណប័ណ្ណ ឬសៀវភៅគ្រួសារ ឬលិខិតឆ្លងដែន ឬឯកសារគតិយុត្តសមមូលផ្សេងទៀត។

## អ្វីជាគ្រោះថ្នាក់ការងារ?

ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារ ចំពោះគ្រោះថ្នាក់ទាំងឡាយណាដែលធ្លាក់លើរូបកាយកម្មករនិយោជិត ដូចខាងក្រោម៖

១- គ្រោះថ្នាក់ក្នុងពេលធ្វើការ

២- គ្រោះថ្នាក់ពេលធ្វើដំណើរ ពីលំនៅដ្ឋានត្រង់ឆ្ពោះទៅកន្លែងធ្វើការ បុរិលមកវិញដោយគ្មានឈប់ ឬគ្មានវាងទៅកន្លែងណាផ្សេងជាប្រយោជន៍ផ្ទាល់ខ្លួន ឬក្រៅពីការងារដែលគេតម្រូវអោយទៅ។

៣- ជំងឺវិជ្ជាជីវៈ។

## តើពេលគ្រោះថ្នាក់ការងារត្រូវធ្វើដូចម្ដេច?



| ទំនាក់ទំនងបន្ទាន់ (HotLine)<br>(ករណីគ្រោះថ្នាក់ការងារ) |
|---|
| 1286 |
| ទំនាក់ទំនងព័ត៌មាន |
| ០២៣ ៨៨២ ៦២៣<br>០២៣ ៨៨២ ៨៣៤ |

១- កម្មករនិយោជិត ត្រូវជូនដំណឹងទៅនិយោជក ឬក្នុងករណីសង្គ្រោះបន្ទាន់ អាចទំនាក់ទំនងផ្ទាល់មក ប.ស.ស តាមរយៈប្រព័ន្ធទូរស័ព្ទទំនាក់ទំនងបន្ទាន់ Hotline ១២៨៦។

២- និយោជក ឬម្ចាស់សហគ្រាស ត្រូវជូនដំណឹងមកបេឡាជាតិរបបសន្តិសុខសង្គមក្នុងរយៈពេលយ៉ាងយូរបំផុត៤៨ ម៉ោង នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលដំណឹងពីជនរងគ្រោះ។

៣- ការជូនដំណឹងហានិភ័យការងារជាបឋម អាចធ្វើតាមរយៈសារអេឡិចត្រូនិច (E-mail: benefit@nssf.gov.kh) បន្ទាប់មក ត្រូវធ្វើតាមទម្រង់របាយការណ៍ហានិភ័យការងារបញ្ជូនមក ប.ស.ស ផ្ទាល់ ។

# បេឡាជាតិរបបសន្តិសុខសង្គម
## ( ប.ស.ស )

## ឆាកព៌ម៉ាំងគ្រោះថ្នាក់ការងារ




ទូរស័ព្ទលេខ៖ ០២៣ ៨៨២ ៦២៣/ ៨៨២ ៨៣៤

ទូរសារ៖ ០២៣ ៨៨២ ៦២៣

ទូរស័ព្ទទំនាក់ទំនងបន្ទាន់ (Hot Line )៖ ១២៨៦

គេហទំព័រ៖ www.nssf.gov.kh

សារអេឡិចត្រូនិច៖ info@nssf.gov.kh

# លេខទូរស័ព្ទសម្រាប់ទំនាក់ទំនង

*លេខទូរស័ព្ទសម្រាប់ទំនាក់ទំនងជាមួយមន្ទីរពេទ្យ*

| ឈ្មោះមន្ទីរពេទ្យ | ម៉្យានសាម៉ុយ | ទូរស័ព្ទមាន់បេតុការណ៍ |
|---|---|---|
| មន្ទីរពេទ្យកាល់ម៉ែត | ១១៩ | ០២៣ ៤២ ៦៩ ៤៨ |
| មន្ទីរពេទ្យព្រះកុសុមៈ | ១១៩ | ០១២ ៦៥៧ ៦៥៣ |
| មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត | ១១៩ | ០២៣ ២១៧ ៧៦៤ |
| មន្ទីរពេទ្យជ័យជំនះ | ០១៥៥១៩-១១៩ | ០១២ ៩១២ ៥២៣ |
| មន្ទីរពេទ្យបង្អែកកំពង់ស្ពឺ | ០១៦៦៩៦-៤៨០ | ០២៥ ៩៨៧ ៣១៣ |
| មណ្ឌលសុខភាពបែកចាន | | ០១២ ៨៩៤ ២៦០ |
| មន្ទីរពេទ្យបង្អែកស្វាយរៀង | ០៤៤ ៩៤៥ ១១១ | ០១២ ៩៥៣ ៩៧៥ |
| មន្ទីរពេទ្យបង្អែកជីក្រែង | ០១១ ៣៩៤ ១៧៨ | ០១២ ៨០៥ ២៣៦ |
| មន្ទីរពេទ្យបង្អែកកំពង់ឆ្នាំង | ០២៦ ៩៨៨ ១១១ | ០១៥ ២៥០ ១១១ |
| មន្ទីរពេទ្យបង្អែកកំពង់ត្របែក | ០៨៥ ៥៨៧ ៧៥៧ | ០៨៥ ៥៨៧ ៧៩០ |
| មន្ទីរពេទ្យបង្អែកសៀមរាប | ០១៦ ៨០០ ១១៩ | ០១២ ៩២៥ ០៦១ |
| មន្ទីរពេទ្យបង្អែកអូរាំងឪ | ០១២ ៧៨៦ ២៨៦ | ០៨៩ ៨៣៧ ៦៣៧ |
| មន្ទីរពេទ្យបង្អែកខេត្តមិត្តភាពកម្ពុជា-ជប៉ុន | ០១២ ៩៣២ ៥២១ | ០១២ ៩២៣ ៣៥៤ |
| មន្ទីរពេទ្យបង្អែកសិរីសោភ័ណ | ០១២ ៩១០ ៨៦៧ | ០១២ ៨៥៤ ៩៨៣ |
| មន្ទីរពេទ្យបង្អែកខេត្តព្រះសីហនុ | ០១៦ ៦៨៦ ៨៤៣ | ០១២ ៧១២ ៦៤៦ |
| មន្ទីរពេទ្យ CT (ខេត្តព្រះសីហនុ) | | ០៨១ ៨៨ ៦៦ ៦៦ |

*លេខទូរស័ព្ទសម្រាប់ទំនាក់ទំនងភ្នាក់ងារ ប.ស.ស តាមមន្ទីរពេទ្យ*

| ភ្នាក់ងារ ប.ស.ស ប្រចាំមន្ទីរពេទ្យ | លេខទូរស័ព្ទ |
|---|---|
| មន្ទីរពេទ្យកាល់ម៉ែត | ០៩៧ ៦៨៧ ២៤២ ៦ |
| មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត | ០៩៧ ៦៨៧ ២៤២ ៧ |
| មន្ទីរពេទ្យជ័យជំនះ (ខេត្តកណ្ដាល) | ០៩៧ ៦៨៧ ២៤២ ៨ |
| មន្ទីរពេទ្យព្រះកុសុមៈ | ០៩៧ ៦៨៧ ២៤២ ៩ |
| មន្ទីរពេទ្យបង្អែកកំពង់ស្ពឺ | ០៩៣ ៧៨ ៣៩ ៣៩ ១ |
| មណ្ឌលសុខភាពបែកចាន | ០៩៣ ៧៨ ៣៨ ៧៦ ៥ |
| មន្ទីរពេទ្យបង្អែកជីក្រែង (ខេត្តស្វាយរៀង) | ០៩៣ ៧៨ ៣៨ ៧៥ ៩ |
| មន្ទីរពេទ្យបង្អែកកំពង់ត្របែក | ០៨៨ ៩៧ ២១ ០១ ៦ |
| មន្ទីរពេទ្យបង្អែកសៀមរាប | ០៨៨ ៩៧ ២១ ០១ ២ |
| មន្ទីរពេទ្យបង្អែកអូរាំងឪ | ០៨៨ ៩៧ ២១ ០១ ៣ |
| មន្ទីរពេទ្យបង្អែកខេត្តព្រះសីហនុ | ០៨៨ ៩៧ ២១ ០១ ៤ |

# គាំទ្រភាលិក ( អត្ថប្រយោជន៍ ) ហានិភ័យការងារ

## សេវាសង្គ្រោះបន្ទាន់




## ការថែទាំ និងការព្យាបាល









## សេវាបុនីតិសម្បទា












## ការផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃ



## ការផ្តល់ប្រាក់វិភាជន៍ ជាសោហ៊ុយបូជាសព




## ការផ្តល់ប្រាក់វិភាជន៍ និងប្រាក់ធនលាភ សម្រាប់ការបាត់បង់សមត្ថភាព ការងារជាអចិន្ត្រៃយ៍ ក្រោម២០% និង២០% ឡើង





## គាំទ្រភាលិកសម្រាប់អ្នកចាំថែរក្សាជនរងគ្រោះ



## គាំទ្រភាលិកឧត្តរជីវី សម្រាប់អ្នករស់នៅក្នុងបន្ទុកនៃជនរងគ្រោះ



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ:......១១៥.......កប/ប្រ.ក

# ប្រកាស

# ស្តីពី

# តាងកាលិកហានិភ័យការងារ

## ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ០៧០៤-១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសំរាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ/បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យ លេខ ៥២ អនក្រ/បក ចុះថ្ងៃទី០១ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ៚

- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ/បក ចុះថ្ងៃទី ០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- យោងតាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម

## សម្រេច

### ប្រការ ១.- សិទ្ធិទទួលបានតាវកាលិកហានិភ័យការងារ

១.១ កម្មករនិយោជិតទាំងអស់នៃសហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជិកាក្នុងបេឡាជាតិរបបសន្តិសុខសង្គម មានសិទ្ធិទទួលបានតាវកាលិកហានិភ័យការងារ នៅពេលដែលសាមីជនទទួលរងនូវហានិភ័យការងារ ។

១.២ ហានិភ័យការងារ រួមមាន គ្រោះថ្នាក់ការងារ គ្រោះថ្នាក់នៅពេលធ្វើដំណើរដោយត្រង់ទៅកន្លែងធ្វើការ ឬមកពីកន្លែងធ្វើការឆ្ពោះទៅលំនៅស្ថាន និងជំងឺវិជ្ជាជីវៈ ។

១.៣ តាវកាលិកដែលកំណត់ក្នុងប្រកាសនេះត្រូវនៅក្នុងបន្ទុករបស់បេឡាជាតិរបបសន្តិសុខសង្គម ។

១.៤ មន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាល ឬគ្រូពេទ្យព្យាបាល ត្រូវមានការទទួលស្គាល់ពីបេឡាជាតិរបបសន្តិសុខសង្គម ។

### ប្រការ ២.- ការជូនដំណឹងហានិភ័យការងារ

២.១ បន្ទាប់ពីបានទទួលដំណឹងពីកម្មករនិយោជិតដែលជាអ្នករងនូវហានិភ័យការងារ ឬអ្នកតំណាងអ្នករងគ្រោះ និយោជកឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ ដែលស្ថិតនៅក្នុងដែនអនុវត្តនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសំរាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដែលបានចុះបញ្ជិកានៅក្នុងបេឡាជាតិរបបសន្តិសុខសង្គម ត្រូវជូនដំណឹងអំពីឧបទ្ទវហេតុនោះទៅបេឡាជាតិរបបសន្តិសុខសង្គមក្នុងរយៈពេលយ៉ាងយូរបំផុត ៤៨ (សែសិបប្រាំបី) ម៉ោងនៃថ្ងៃធ្វើការ ។

២.២ ការជូនដំណឹងហានិភ័យការងារត្រូវធ្វើតាមទម្រង់បែបបទដែលមានកំណត់នៅក្នុងប្រកាសរួមរវាងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសុខាភិបាល ។

### ប្រការ ៣.- ការអង្កេតហានិភ័យការងារ

៣.១ បន្ទាប់ពីទទួលបានរបាយការណ៍ហានិភ័យការងារ ការិយាល័យតាវកាលិក ឬការិយាល័យខេត្តក្រុងនៃបេឡាជាតិរបបសន្តិសុខសង្គម ត្រូវជូនដំណឹងជាបន្ទាន់ទៅអធិការ ឬអភិបាលសន្តិសុខសង្គម ។

២

អធិការ ឬអភិបាលសន្តិសុខសង្គម ត្រូវធ្វើអង្កេត និងផ្តល់លទ្ធផលលើករណីនីមួយៗមកការិយាល័យតាវកាលិកឱ្យបានយ៉ាងឆាប់បំផុត ។

៣.២ ចំពោះករណីដែលមានលក្ខណៈស្មុគស្មាញ អធិការ ឬអភិបាលសន្តិសុខសង្គមអាចស្នើសុំជំនួយពីអ្នកឯកទេស ឬសុំកិច្ចសហការពីអធិការ ឬអភិបាលការងារ ។ ការចំណាយសម្រាប់ផ្នែកនេះ គឺជាបន្ទុករបស់បេឡាជាតិរបបសន្តិសុខសង្គម ។

៣.៣ ចំពោះគ្រោះថ្នាក់ពេលធ្វើដំណើរ អធិការ ឬអភិបាលសន្តិសុខសង្គមត្រូវស្នើសុំព័ត៌មានដែលទាក់ទងនឹងទីកន្លែង ពេលវេលា មូលហេតុនៃគ្រោះថ្នាក់ពីសាក្សី ឬអាជ្ញាធរមានសមត្ថកិច្ចនៅនឹងកន្លែងកើតហេតុ ។

## ប្រការ ៤.- ការផ្តល់សេវាសង្គ្រោះបន្ទាន់

ក្នុងករណីដែលគ្រោះថ្នាក់កើតនៅនឹងកន្លែងធ្វើការ និយោជកត្រូវផ្តល់ការសង្គ្រោះបន្ទាន់ ដែលនៅកន្លែងដែលជិតបំផុត និងបន្ទាប់មកត្រូវបញ្ជូនជនរងគ្រោះទៅមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាល ដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គម ។ ការចំណាយលើការសង្គ្រោះបន្ទាន់ និងការបញ្ជូនខាងលើត្រូវស្ថិតនៅក្នុងបន្ទុករបស់បេឡាជាតិរបបសន្តិសុខសង្គម ។ ក្នុងករណីដែលគ្រោះថ្នាក់នៅពេលធ្វើដំណើរ សាមីជន ឬនិយោជកអាចទាមទារការទូទាត់សង លើការចំណាយសម្រាប់ការសង្គ្រោះនេះពីបេឡាជាតិរបបសន្តិសុខសង្គម ។

## ប្រការ ៥.- ការផ្តល់សេវាថែទាំ និងព្យាបាល

៥.១ ការព្យាបាលចំពោះកម្មករនិយោជិត ដែលរងគ្រោះដោយហានិភ័យការងារត្រូវតែប្រព្រឹត្តទៅនៅក្នុងមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គម ។

៥.២ កម្មករនិយោជិត ដែលទទួលរងហានិភ័យការងារ មានសិទ្ធិទទួលបាន ការពិនិត្យព្យាបាល ការសម្រាកព្យាបាល នៅតាមបណ្តាមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គម ផ្អែកលើកិច្ចព្រមព្រៀងរវាងបេឡាជាតិរបបសន្តិសុខសង្គមជាមួយនឹងមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលសាមី ។

៥.៣ ក្នុងករណីដែល គ្រូពេទ្យព្យាបាលតម្រូវឱ្យទិញឱសថ ឬ សំភារៈឧបករណ៍ដែលចាំបាច់សម្រាប់ការថែទាំ និងព្យាបាលដែលពុំមានចែងនៅក្នុងកិច្ចព្រមព្រៀង បេឡាជាតិរបបសន្តិសុខសង្គមអាចទូទាត់សងទៅជនរងគ្រោះ ឬអ្នកតំណាងវិញបាន លុះណាតែមានវេជ្ជបញ្ជា និងវិក្កយបត្រត្រឹមត្រូវ ។

៥.៤ នាយកបេឡាជាតិរបបសន្តិសុខសង្គម ត្រូវរៀបចំបញ្ជីមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលដែលមានលក្ខណៈសម្បត្តិសមស្របតាមបទដ្ឋានបច្ចេកទេសវេជ្ជសាស្ត្រ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលនៃបេឡា

ជាតិរបបសន្តិសុខសង្គមអនុម័តយល់ព្រម ។

**ប្រការ ៦.- ការគណនាប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ**

៦.១ ប្រាក់ឈ្នួលមធ្យម គឺជាផលចែកមធ្យមភាគនៃប្រាក់ឈ្នួលជាប់ភាគទានក្នុងរយៈពេល ០៦ (ប្រាំមួយ) ខែ មុនកាលបរិច្ឆេទនៃគ្រោះថ្នាក់ ។ ប្រាក់ឈ្នួលជាប់ភាគទាន ត្រូវបានកំណត់ក្នុងតារាងដូចមានចែងក្នុង**ឧបសម្ព័ន្ធ ១** នៃប្រកាសនេះ ។

៦.២ ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ គឺជាផលចែកនៃប្រាក់ឈ្នួលមធ្យមដូចមានចែងក្នុងចំណុច ៦.១ នឹង ៣០ (សាមសិប) ថ្ងៃ ។

៦.៣ ការគណនាប្រាក់ឈ្នួលមធ្យម ដែលកំណត់នៅក្នុងប្រកាសនេះមានអានុភាពចំពោះតែការគណនាតាវកាលិកសន្តិសុខសង្គមប៉ុណ្ណោះ ។

**ប្រការ ៧.- ការផ្តល់តាវកាលិកសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន**

៧.១ រយៈពេលនៃការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន ត្រូវបានកំណត់ដូចតទៅ:

- រយៈពេលនៃការសម្រាកព្យាបាលមុខរបួស ឬជំងឺវិជ្ជាជីវៈនៅក្នុងមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាល
- រយៈពេលនៃការសម្រាកក្រោយពេលមុខរបួសជាសះស្បើយតាមវេជ្ជបញ្ជា ។

៧.២ ក្នុងរយៈពេលនៃការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន ដូចមានចែងក្នុងវាក្យខណ្ឌ ៧.១ ខាងលើ កម្មករនិយោជិត ដែលរងគ្រោះដោយហានិភ័យការងារមានសិទ្ធិទទួលបានតាវកាលិកពីបេឡាជាតិរបបសន្តិសុខសង្គម ដូចតទៅ:

- ប្រាក់បំណាច់ប្រចាំថ្ងៃ ដែលត្រូវផ្តល់ជូនគិតចាប់ពីថ្ងៃទីពីរ បន្ទាប់ពីកាលបរិច្ឆេទនៃការកើតឧបទ្ទវហេតុបណ្តាលឱ្យទទួលរងនូវហានិភ័យការងារ
- ប្រាក់ឧបត្ថម្ភសម្រាប់អ្នកថែទាំអ្នករងគ្រោះពេលសម្រាកព្យាបាលនៅមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាល ក្នុងករណី ដែលស្ថានភាពគ្រោះថ្នាក់ធ្ងន់ធ្ងរតម្រូវឱ្យមានអ្នកនៅចាំថែទាំ តាមសំណើសុំរបស់គ្រូពេទ្យព្យាបាល ។

៧.៣ ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្នត្រូវផ្តល់ចំពោះតែហានិភ័យការងារ ដែលតម្រូវឱ្យមានការសម្រាកព្យាបាលលើសពី ០៤ (បួន) ថ្ងៃឡើងទៅ ។

៧.៤ ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្នត្រូវស្មើនឹង ៧០ (ចិតសិប) ភាគរយ នៃប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ ។ ប្រាក់ឧបត្ថម្ភសម្រាប់អ្នកថែទាំនៅមន្ទីរពេទ្យ ត្រូវស្មើនឹង ៥០ (ហាសិប) ភាគរយនៃប្រាក់បំណាច់ប្រចាំថ្ងៃរបស់ជនរងគ្រោះ ។ ៩៥ -

៧.៥ ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន អាចផ្តល់ជូនជនរងគ្រោះដោយហានិភ័យការងារ ក្នុងរយៈពេលយ៉ាងយូរបំផុត ១៨០ ( មួយរយប៉ែតសិប ) ថ្ងៃ ។

**ប្រការ ៨.- ប្រាក់កាលិកសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍**

៨.១ កម្មករនិយោជិតដែលទទួលរងហានិភ័យការងារបណ្តាលឱ្យបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍តិចជាង ២០ ភាគរយ មានសិទ្ធិទទួលបានប្រាក់វិភាជន៍សម្រាប់ការបាត់បង់សមត្ថភាពការងារ ។ ប្រាក់វិភាជន៍នេះត្រូវផ្តល់ជូនអ្នករងគ្រោះតែម្តងគត់ ដោយគិតតាមរូបមន្តដូចខាងក្រោម:

**វបក** = **បឈម** x ៧០% x **កបក** x ២០% **មតប**

- **វបក:** វិភាជន៍បាត់បង់សមត្ថភាពការងារ
- **បឈម:** ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃរបស់ជនរងគ្រោះ
- **កបក:** កម្រិតបាត់បង់សមត្ថភាពការងាររបស់ជនរងគ្រោះ
- **មតប:** មេគុណតម្លៃបច្ចុប្បន្ន

៨.២ កម្មករនិយោជិតដែលទទួលរងហានិភ័យការងារបណ្តាលឱ្យបាត់បង់សមត្ថភាពការងារចាប់ពី ២០ ភាគរយឡើង មានសិទ្ធិទទួលបានធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ ។ប្រាក់ធនលាភសរុបសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ ត្រូវបានគិតតាមរូបមន្តដូចខាងក្រោម:

**ធល** = **បឈម** x ៧០ % x [**កបក** − ១/៥ **កបក**] x **មតប**

- **ធល:** ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារ

៨.៣ ប្រាក់ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ ត្រូវចាត់ទុកជាបណ្តោះអាសន្នជានិច្ច ។ បេឡាជាតិរបបសន្តិសុខសង្គម ត្រូវរៀបចំឱ្យមានការពិនិត្យសុខភាព និងសមត្ថភាពការងារអ្នករងគ្រោះឡើងវិញក្នុងរយៈពេល ១ (មួយ) ឆ្នាំយ៉ាងយូរ ។ ជនរងគ្រោះដែលទទួលបានប្រាក់ធនលាភត្រូវមានកាតព្វកិច្ចមកពិនិត្យសុខភាពតាមការកំណត់របស់បេឡាជាតិរបបសន្តិសុខសង្គម ។

៨.៤ កម្រិតនៃការបាត់បង់សមត្ថភាពការងារ ត្រូវបានកំណត់នៅក្នុង **ឧបសម្ព័ន្ធ ២** នៃប្រកាសនេះ ។ មេគុណតម្លៃបច្ចុប្បន្ន ត្រូវបានកំណត់នៅក្នុង **ឧបសម្ព័ន្ធ ៣** ។

**ប្រការ ៩.- ប្រាក់បន្ថែមសម្រាប់អ្នកចាំថែរក្សាជនរងគ្រោះ**

កម្មករនិយោជិត ដែលទទួលរងហានិភ័យការងារបណ្តាលឱ្យបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ក្នុងកម្រិត ១០០ ភាគរយ មានសិទ្ធិទទួលបានប្រាក់បន្ថែមសម្រាប់អ្នកចាំថែរក្សាផ្ទាល់ខ្លួន ។ ប្រាក់បន្ថែម ទាំ -

សម្រាប់អ្នកចាំថែរក្សាត្រូវស្មើ ៥០ (ហាសិប) ភាគរយនៃប្រាក់ធនលាភរបស់ជនរងគ្រោះ ។

**ប្រការ ១០.- ប្រាក់វិភាជន៍ជាសោហ៊ុយបូជាសព**

ក្នុងករណីដែលមានការទទួលរងនូវហានិភ័យការងាររហូតបណ្តាលឱ្យបាត់បង់ជីវិត អ្នកទទួលរ៉ាប់រងក្នុងការចាត់ចែងបូជាសព ត្រូវបានផ្តល់ប្រាក់វិភាជន៍ជាសោហ៊ុយបូជាសព ដែលមានចំនួន ១.000.000 (មួយលាន) រៀល ។ ប្រាក់វិភាជន៍នេះ ត្រូវតែផ្តល់ជូនទៅជន ដែលទទួលបន្ទុកផ្ទាល់ក្នុងការចាត់ចែងបូជាសពជនរងគ្រោះ ។

**ប្រការ ១១.- តាវកាលិកឧត្តរជីវី**

១១.១ ឧត្តរជីវីនៃជនរងគ្រោះដោយហានិភ័យការងារដូចមានចែងនៅក្នុងមាត្រា ៣៤ នៃអនុក្រឹត្យលេខ ១៦ អនក្រ/បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គមមានសិទ្ធិទទួលបានតាវកាលិកឧត្តរជីវី ។

១១.២ តាវកាលិកឧត្តរជីវី គឺជាប្រាក់ធនលាភដែលត្រូវផ្តល់ឱ្យសិទ្ធិវន្តនៃជនរងគ្រោះ តាមអត្រាដូចខាងក្រោម:

ក. ក្នុងករណីសិទ្ធិវន្ត មានរួមទាំងប្រពន្ធ ឬប្តី កូន និងឪពុកម្តាយ ឬមនុស្សចាស់ជរានៅក្នុងបន្ទុក

- ប្រពន្ធ ឬប្តី = ៣/៥ x ៦៣% បលឈម
- ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក= ២/៥ x ៦៣% បលឈម
- ធនលាភសរុបសម្រាប់ឪពុកម្តាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក = ៧% បលឈម

ខ. ក្នុងករណីសិទ្ធិវន្ត មានតែប្រពន្ធ ឬប្តី និង/ឬ កូន

- ប្រពន្ធ ឬប្តី = ៣/៥ x ៧០%បលឈម
- ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក = ២/៥ x ៧០%បលឈម

គ. ក្នុងករណីសិទ្ធិវន្តមានតែឪពុកម្តាយ ឬមនុស្សចាស់ជរា

- ធនលាភសរុបសម្រាប់ឪពុកម្តាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក = ២៨%បលឈម

ឃ. ក្នុងករណីសិទ្ធិវន្ត មានតែកូន និងឪពុកម្តាយ ឬមនុស្សចាស់ជរា

- ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក = ២៨%បលឈម
- ធនលាភសរុបសម្រាប់ឪពុកម្តាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក = ២៨%បលឈម

ង. ក្នុងករណីសិទ្ធិវន្តមានតែ ប្រពន្ធ ឬប្តី និងឪពុកម្តាយ ឬមនុស្សចាស់ជរា

- ប្រពន្ធ ឬប្តី = ២៨%បលឈម
- ធនលាភសរុបសម្រាប់ឪពុកម្តាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក = ២៨%បលឈម

១១.៣ សិទ្ធិវន្ត ជាប្រពន្ធ ឬប្តីនៃជនរងគ្រោះ ត្រូវមានលិខិតបញ្ជាក់អាពាហ៍ពិពាហ៍។ សិទ្ធិទទួលធនលាភចំពោះសិទ្ធិវន្តដែលជាប្រពន្ធ ឬប្តី ត្រូវបានរំលាយនៅពេលដែលសាមីជនរៀបអាពាហ៍ពិពាហ៍ជាថ្មី។ ក្នុងករណីនៃការរៀបអាពាហ៍ពិពាហ៍ជាថ្មី សាមីជនត្រូវជូនដំណឹងមកបេឡាជាតិរបបសន្តិសុខសង្គមយ៉ាងយូរបំផុត ៣០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការចុះលិខិតបញ្ជាក់អាពាហ៍ពិពាហ៍។ ការខកខានមិនបានជូនដំណឹងអំពីការរៀបអាពាហ៍ពិពាហ៍របស់ខ្លួន សាមីជននឹងត្រូវទទួលទោសដូចមានចែងក្នុងមាត្រា ៣៨ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

១១.៤ សិទ្ធិវន្តជា កូនត្រូវមានស្ថានភាពស្របតាមលក្ខខណ្ឌដូចមានចែងនៅក្នុងចំណុច ៣៤.១ ខ មាត្រា ៣៤ នៃអនុក្រឹត្យលេខ១៦ អនក្រ/បកចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧។

១១.៥ សិទ្ធិទទួលធនលាភនៃសិទ្ធិវន្ត ត្រូវបានរំលាយនៅពេលដែលសាមីជនទទួលមរណភាព។

**ប្រការ ១២.- សេវាបុនរ៍និតិសម្បទា**

១២.១កម្មករនិយោជិតដែលរងហានិភ័យការងារបណ្តាលឱ្យបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ មានសិទ្ធិទទួលបានឧបករណ៍ ឬអវៈយវៈសិប្បនិម្មិតតាមការកំណត់របស់គ្រូពេទ្យផ្លូវការឬគ្រូពេទ្យដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គម។

១២.២កម្មករនិយោជិតដែលរងហានិភ័យការងារបណ្តាលឱ្យបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ មានសិទ្ធិទទួលបានសេវាសម្របសម្រួលមុខងារ និងការបណ្តុះបណ្តាលវិជ្ជាជីវៈឡើងវិញ ស្របតាមលក្ខខណ្ឌដែលនឹងកំណត់ក្នុងប្រកាសដោយឡែករបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**ប្រការ ១៣.- ការទាមទារតាវការលិក**

១៣.១ ការទាមទារតាវកាលិកសម្រាប់ការថែទាំ និងព្យាបាល អាចត្រូវបានធ្វើឡើងដោយមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលដែលព្យាបាលជនរងគ្រោះ ឬនិយោជក ឬក៏កម្មករនិយោជិតជាជនរងគ្រោះផ្ទាល់តាមទម្រង់ "**តាវកាលិកថែទាំ និងព្យាបាល**" ឬហៅថាទម្រង់ " ៣.០២ "ដូចមានចែងក្នុង **ឧបសម្ព័ន្ធ ៤** នៃប្រកាសនេះ។

១៣.២ ការទាមទារប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្នត្រូវធ្វើដោយជនរងគ្រោះ ឬតំណាងតាមទម្រង់ "**តាវកាលិកបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន** " ឬហៅថាទម្រង់ "៣.០៣ " ដូចមានចែងក្នុង **ឧបសម្ព័ន្ធ ៥** នៃប្រកាសនេះ។ រំលបបទ នៃការទាមទារនេះត្រូវមានភ្ជាប់ជាមួយនូវវេជ្ជបញ្ជា និងលិខិតបញ្ជាក់ពីគ្រូពេទ្យព្យាបាលផ្លូវការ។

១៣.៣ ការទាមទារតាវកាលិកសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ ត្រូវធ្វើឡើងដោយជនរងគ្រោះតាមទម្រង់ "**តាវកាលិកបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍** " ឬហៅថាទម្រង់ ៣.០៤

"៣.០៤ " ដូចមានចែងក្នុង**ឧបសម្ព័ន្ធ ៦** នៃប្រកាសនេះ។ ក្នុងករណីដែល ជនរងគ្រោះមិនអាចមានសមត្ថភាព ក្នុងការទាមទារតាវកាលិកបាន ដោយសារស្ថានភាពនៃការបាត់បង់សមត្ថភាពការងារធ្ងន់ធ្ងរ ការទាមទារនេះអាចត្រូវធ្វើដោយអ្នកតំណាងជនរងគ្រោះ។ អ្នកតំណាងជនរងគ្រោះ អាចជាប្ដី ប្រពន្ធ កូន ឬជន ដែលមានភារៈថែរក្សាដោយផ្ទាល់ចំពោះជនរងគ្រោះ។

១៣.៤ ការទាមទារតាវកាលិកឧត្តរជីវី និងសោហ៊ុយបូជាសព ត្រូវធ្វើដោយសិទ្ធិវន្តនៃជនរងគ្រោះ ឬអ្នកតំណាង តាមទម្រង់ "**តាវកាលិកឧត្តរជីវី** " ឬហៅថាទម្រង់ " **៣.០៥** " និងទម្រង់ " **វិភាជន៍បូជាសព**" " ឬហៅថា ទម្រង់ "**៣.០៦** " ដូចមានចែងក្នុង **ឧបសម្ព័ន្ធ ៧ និង ៨** នៃប្រកាសនេះ។

១៣.៥ សិទ្ធិនៃការទាមទារប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ហានិភ័យការងារ និងប្រាក់វិភាជន៍បូជាសព ត្រូវអស់សុពលភាពត្រឹមរយៈពេល ១ (មួយ) ឆ្នាំ។ ចំពោះសិទ្ធិក្នុងការទាមទារប្រាក់ធនលាភ ត្រូវអស់សុពលភាពត្រឹមរយៈពេល ៥ (ប្រាំ) ឆ្នាំ។

១៣.៦ ការបើកប្រាក់ធនលាភ ត្រូវធ្វើប្រចាំត្រីមាស។

## ប្រការ ១៤.- ការយល់ព្រមចំពោះការទាមទារតាវកាលិក

១៤.១ តាវកាលិកថែទាំ និងព្យាបាល ដែលត្រូវបានទទួលការយល់ព្រមពីបេឡាជាតិរបបសន្តិសុខសង្គម លុះណាតែការថែទាំនិងព្យាបាលនោះធ្វើនៅក្នុងមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គម។

ប្រសិនបើការថែទាំ និងព្យាបាលធ្វើនៅមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលផ្សេងក្រៅពីការកំណត់របស់បេឡាជាតិរបបសន្តិសុខសង្គម ការទូទាត់សងវិញត្រូវធ្វើតាមអត្រាតម្លៃដែលបេឡាជាតិរបបសន្តិសុខសង្គមបានកំណត់។

តារាងតម្លៃសម្រាប់ការថែទាំ និងព្យាបាល ត្រូវបានកំណត់តាមកិច្ចព្រមព្រៀងរវាងបេឡាជាតិរបបសន្តិសុខសង្គម និងបណ្ដាមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាល។

១៤.២ ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្ដោះអាសន្ន ដែលត្រូវបានទទួលការយល់ព្រមពីបេឡាជាតិរបបសន្តិសុខសង្គម លុះណាតែការទាមទារនោះស្របនឹងលក្ខខណ្ឌដូចមានចែងក្នុងប្រការ ៧ វាក្យខ័ណ្ឌ ៧.១, ៧.២ និង ៧.៣ នៃប្រកាសនេះ។

១៤.៣ តាវកាលិកសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ ត្រូវបានយល់ព្រម លុះត្រាតែការបាត់បង់សមត្ថភាពនោះត្រូវបានវាយតម្លៃពីគ្រូពេទ្យផ្លូវការ ឬ គណៈកម្មការវេជ្ជសាស្ត្រនៃបេឡាជាតិរបបសន្តិសុខសង្គម ស្របតាមតារាងនៃកម្រិតបាត់បង់សមត្ថភាពការងារដូចមានចែងក្នុង**ឧបសម្ព័ន្ធ ២** នៃប្រកាសនេះ។ក្នុងករណីដែល កម្រិតបាត់បង់សមត្ថភាពការងារពុំមានចែងនៅក្នុងតារាងខាងលើ គណៈកម្មការ

វេជ្ជសាស្ត្រ ត្រូវវាយតម្លៃកម្រិតបាត់បង់សមត្ថភាពតាមបច្ចេកទេសវេជ្ជសាស្ត្រ ដោយមានការចូលរួមពីគ្រូពេទ្យឯកទេសតាម ស្ថានភាពជាក់ស្តែងនីមួយៗ។

**ប្រការ ១៥.- អន្តរប្បញ្ញត្តិ**

ចំពោះសហគ្រាស គ្រឹះស្ថានដែលពុំទាន់ត្រូវបានចុះបញ្ជិកានៅក្នុងបេឡាជាតិរបបសន្តិសុខសង្គមការផ្តល់តាវកាលិកសម្រាប់ហានិភ័យការងារ ត្រូវបន្តអនុវត្តតាមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ។

**ប្រការ ១៦.- អវសានប្បញ្ញត្តិ**

ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែ[illegible] ឆ្នាំ២០០៨

**រដ្ឋមន្ត្រី**

**វង សូត**

**ចម្លងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ "ដើម្បីជូនជ្រាប"
- កាលប្បវត្តិ និងឯកសារ

៩

ឧបសម្ព័ន្ធ ១ នៃប្រកាសលេខ ១០៩ កប/ប្រក ស្តីពីតាវកាលិកហានិភ័យការងារ

## តារាងប្រាក់ឈ្នួលជាប់ភាគទាន

| ថ្នាក់ | ចំនួនប្រាក់ឈ្នួលសរុប (រៀល) | ប្រាក់ឈ្នួលជាប់ភាគទាន(រៀល) |
|---|---|---|
| ១ | តិចជាង ២០០.០០០ | ២០០.០០០ |
| ២ | ២០០.០០១ -២៥០.០០០ | ២២៥.០០០ |
| ៣ | ២៥០.០០១-៣០០.០០០ | ២៧៥.០០០ |
| ៤ | ៣០០.០០១-៣៥០.០០០ | ៣២៥.០០០ |
| ៥ | ៣៥១.០០១-៤០០.០០០ | ៣៧៥.០០០ |
| ៦ | ៤០០.០០១-៤៥០.០០០ | ៤២៥.០០០ |
| ៧ | ៤៥០.០០១-៥០០.០០០ | ៤៧៥.០០០ |
| ៨ | ៥០០.០០១-៥៥០.០០០ | ៥២៥.០០០ |
| ៩ | ៥៥០.០០១-៦០០.០០០ | ៥៧៥.០០០ |
| ១០ | ៦០០.០០១-៦៥០.០០០ | ៦២៥.០០០ |
| ១១ | ៦៥០.០០១-៧០០.០០០ | ៦៧៥.០០០ |
| ១២ | ៧០០.០០១-៧៥០.០០០ | ៧២៥.០០០ |
| ១៣ | ៧៥០.០០១-៨០០.០០០ | ៧៧៥.០០០ |
| ១៤ | ៨០០.០០១-៨៥០.០០០ | ៨២៥.០០០ |
| ១៥ | ៨៥០.០០១-៩០០.០០០ | ៨៧៥.០០០ |
| ១៦ | ៩០០.០០១-៩៥០.០០០ | ៩២៥.០០០ |
| ១៧ | ៩៥០.០០១-១.០០០.០០០ | ៩៧៥.០០០ |
| ១៨ | ១.០០០.០០១ ឡើង | ១.០០០.០០០ |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៣១ អនក្រ.បក

ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
ចូល
លេខ: 3316
ថ្ងៃទី 14.10.11 ម៉ោង
បញ្ជូន

# អនុក្រឹត្យ

## ស្តីពី

## ប្រតិទិនឈប់សម្រាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ ២០១២

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់រដ្ឋធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/ ០៨០៥/៣៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ទៅជា គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត ០៤១១/៣៤០ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១១ ស្តីពីការកែសម្រួលមុខតំណែងសមាសភាពថ្នាក់ដឹកនាំមួយចំនួន នៃគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ
- បានឃើញ អនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការកំណត់ពេលវេលាបម្រើការងារប្រចាំសប្តាហ៍របស់មន្ត្រីរាជការស៊ីវិល ក្នុងព្រះរាជាណាចក្រកម្ពុជា
- បានឃើញ អនុក្រឹត្យលេខ២៥ អនក្រ/បក ចុះថ្ងៃទី២៣ កុម្ភៈ ឆ្នាំ២០១០ ស្តីពីការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ
- តាមសំណើរបស់ប្រធានគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ

# ស ម្រេ ច

**<u>មាត្រា ១.-</u>**

អនុញ្ញាតឱ្យមន្ត្រីរាជការ និយោជិត កម្មករ នៃព្រះរាជាណាចក្រកម្ពុជា បានឈប់សម្រាកការងារឆ្នាំ ២០១២ តាមប្រតិទិន ដូចខាងក្រោម :

| | | | |
|---|---|---|---|
| - ថ្ងៃទី ០១ | មករា | ទិវាចូលឆ្នាំសកល | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ០៧ | មករា | ទិវាជ័យជំនះលើរបបប្រល័យពូជសាសន៍ | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ០៧ | កុម្ភៈ | ពិធីបុណ្យមាឃបូជា | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ០៨ | មីនា | ទិវានារីអន្តរជាតិ | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ១៣-១៤-១៥ | មេសា | ពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ | សម្រាក០៣ ថ្ងៃ |
| - ថ្ងៃទី ០១ | ឧសភា | ទិវាពលកម្មអន្តរជាតិ | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ០៥ | ឧសភា | ពិធីបុណ្យវិសាខបូជា | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ០៩ | ឧសភា | ព្រះរាជពិធីច្រត់ព្រះនង្គ័ល | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ១៣-១៤-១៥ | ឧសភា | ព្រះរាជពិធីបុណ្យចម្រើនព្រះជន្មព្រះករុណាព្រះបាទ **សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** | សម្រាក ០៣ ថ្ងៃ |
| - ថ្ងៃទី ០១ | មិថុនា | ទិវាកុមារអន្តរជាតិ និងទិវាកុមារកម្ពុជា | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ១៨ | មិថុនា | ព្រះរាជពិធីបុណ្យចម្រើនព្រះជន្មសម្តេចព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ២៤ | កញ្ញា | ទិវាប្រកាសរដ្ឋធម្មនុញ្ញ | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ១៤-១៥-១៦ | តុលា | ពិធីបុណ្យភ្ជុំបិណ្ឌ | សម្រាក ០៣ ថ្ងៃ |
| - ថ្ងៃទី ២៩ | តុលា | ព្រះរាជពិធីគ្រងព្រះបរមរាជសម្បត្តិរបស់ព្រះករុណា **ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ៣១ | តុលា | ព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម**ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ** | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ០៩ | វិច្ឆិកា | ពិធីបុណ្យឯករាជ្យជាតិ | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ២៧-២៨-២៩ | វិច្ឆិកា | ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និង សំពះព្រះខែ អកអំបុក | សម្រាក ០៣ ថ្ងៃ |
| - ថ្ងៃទី ១០ | ធ្នូ | ទិវាសិទ្ធិមនុស្សអន្តរជាតិ | សម្រាក ០១ ថ្ងៃ |

**មាត្រា ២.-**

ពេលវេលាឈប់សម្រាកទាំងឡាយដែលត្រូវចំថ្ងៃណាមួយ នៃថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ (សៅរ៍ ឬ អាទិត្យ) ត្រូវបានឱ្យឈប់ចំនួន០១ថ្ងៃ នៃថ្ងៃបន្ទាប់ជាបន្ថែមទៀត។ ប៉ុន្តែ ក្នុងករណីត្រូវចំទាំងពីរថ្ងៃជាប់គ្នា គឺទាំងថ្ងៃសៅរ៍ ទាំងថ្ងៃអាទិត្យនោះ ចំនួនថ្ងៃបន្ទាប់ដែលត្រូវអនុញ្ញាតឱ្យឈប់សម្រាកបន្ថែមជាជំនួស គឺឈប់ចំនួន ០១ ថ្ងៃតែប៉ុណ្ណោះ។

**មាត្រា ៣.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជា និរាករណ៍ ។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន អភិបាលនៃគណៈអភិបាលរាជធានី និងខេត្ត ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេច នាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ 359
ថ្ងៃទី 03 ខែ 11 ឆ្នាំ 11
ម៉ោង 3:20 mn

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ : ៧២៨ ក.ប**

រាជធានីភ្នំពេញ,ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ២០១១

# ប្រកាស
# ស្តីពី
# ការឈប់បុណ្យដែលមានប្រាក់ឈ្នួល ប្រចាំឆ្នាំ២០១២

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឲ្យប្រើច្បាប់រដ្ឋធម្មនុញ្ញបន្ថែមសំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៨០៥/៣៥៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ទៅជាគណៈកម្មការរៀបចំបុណ្យជាតិ-អន្តរជាតិ

-បានឃើញ ព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើ ច្បាប់ស្តីពីការងារ

-បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-បានឃើញ អនុក្រឹត្យលេខ ៥២ អនក្រ/បក. ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-បានឃើញ អនុក្រឹត្យលេខ ២៣១ អនក្រ.បក. ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ២០១១ ស្តីពីប្រតិទិនឈប់សម្រាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ២០១២។

## សម្រេច

**ប្រការ១.** ថ្ងៃបុណ្យដែលត្រូវឈប់ ហើយមានប្រាក់ឈ្នួលនៅ ឆ្នាំ២០១២ ត្រូវអនុញ្ញាតឲ្យកម្មករ និយោជិត នៃសហគ្រាស គ្រឹះស្ថានទាំងអស់ ដែលមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារ បានឈប់សម្រាកការងារ ដោយមានប្រាក់ឈ្នួលតាមការកំណត់ ដូចខាងក្រោម៖

| | | | |
|---|---|---|---|
| - ថ្ងៃទី ០១ | មករា | ទិវាចូលឆ្នាំសកល | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ០៧ | មករា | ទិវាជ័យជំនះលើរបបប្រល័យពូជសាសន៍ | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ០៧ | កុម្ភៈ | ពិធីបុណ្យមាឃបូជា | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ០៨ | មីនា | ទិវានារីអន្តរជាតិ | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ១៣-១៤-១៥ | មេសា | ពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ | សម្រាក ០៣ ថ្ងៃ |
| - ថ្ងៃទី ០១ | ឧសភា | ទិវាពលកម្មអន្តរជាតិ | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ០៥ | ឧសភា | ពិធីបុណ្យវិសាខបូជា | សម្រាក ០១ ថ្ងៃ |

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

| | | | |
|---|---|---|---|
| - ថ្ងៃទី ០៩ | ឧសភា | ព្រះរាជពិធីច្រត់ព្រះនង្គ័ល | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ១៣-១៤-១៥ | ឧសភា | ព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម **ព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** | សម្រាក ០៣ ថ្ងៃ |
| - ថ្ងៃទី ០១ | មិថុនា | ទិវាកុមារអន្តរជាតិ និងទិវាកុមារកម្ពុជា | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ១៨ | មិថុនា | ព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ២៤ | កញ្ញា | ទិវាប្រកាសរដ្ឋធម្មនុញ្ញ | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ១៤-១៥-១៦ | តុលា | ពិធីបុណ្យភ្ជុំបិណ្ឌ | សម្រាក ០៣ ថ្ងៃ |
| - ថ្ងៃទី ២៩ | តុលា | ព្រះរាជពិធីគ្រងព្រះបរមរាជសម្បត្តិរបស់ **ព្រះករុណា ព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ៣១ | តុលា | ព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម **ព្រះករុណា ព្រះបាទសម្តេច នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ** | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ០៩ | វិច្ឆិកា | ពិធីបុណ្យឯករាជ្យជាតិ | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ២៧-២៨-២៩ | វិច្ឆិកា | ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និង សំពះព្រះខែ អកអំបុក | សម្រាក ០៣ ថ្ងៃ |
| - ថ្ងៃទី ១០ | ធ្នូ | ទិវាសិទ្ធិមនុស្សអន្តរជាតិ | សម្រាក ០១ ថ្ងៃ។ |

**ប្រការ២-** ចំពោះសហគ្រាស គ្រឹះស្ថានទាំងឡាយណា ដែលមានថ្ងៃឈប់សម្រាកបុណ្យចំថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ គឺថ្ងៃអាទិត្យ ត្រូវបានឈប់សម្រាកចំនួន ០១ថ្ងៃ នៃថ្ងៃបន្ទាប់ជាបន្ថែមទៀត ។

**ប្រការ៣-** ចំពោះសហគ្រាស គ្រឹះស្ថានទាំងឡាយណា ដែលមានថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ នៅថ្ងៃសៅរ៍ផង និងថ្ងៃអាទិត្យផង ហើយពេលវេលានៃការឈប់សម្រាកបុណ្យនេះ ចំថ្ងៃសៅរ៍ ឬថ្ងៃអាទិត្យ ត្រូវបានឈប់សម្រាកចំនួន ០១ថ្ងៃ នៃថ្ងៃបន្ទាប់ជាបន្ថែមទៀត ។ ប៉ុន្តែក្នុងករណីត្រូវចំថ្ងៃទាំងពីរជាប់គ្នា គឺទាំងថ្ងៃសៅរ៍ ទាំងថ្ងៃអាទិត្យនោះ ត្រូវបានឈប់សម្រាកជំនួសចំនួន ០១ថ្ងៃ តែប៉ុណ្ណោះ។

**ប្រការ៤-** ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១២ តទៅ ។

**រដ្ឋមន្ត្រី**
**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**វង សូត**

**__ចម្លងជូន:__**
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី-ខេត្ត
- គ្រប់សមាគមនិយោជក
- គ្រប់សហព័ន្ធសហជីព
  "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
- កាលប្បវត្តិ - ឯកសារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ:..៩៤០...........កប /ប្រ.ក

# ប្រកាស

## ស្តីពី

## ការកែសម្រួលប្រការ ៧ និងប្រការ ៩ នៃប្រកាសលេខ ១០៩ កប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតារាងកាលិកហានិភ័យការងារ

## ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសំរាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ/បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យ លេខ ៥២ អនក្រ/បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និង ការ

១

ប្រព្រឹត្តទៅរបស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ/បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- បានឃើញប្រកាសលេខ ១០៩ កប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ
- យោងតាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម
- យោងលិខិតលេខ ៣៣៧២ សហវ.ឧហ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ មួយ.-**

ប្រការ ៧ និង ប្រការ ៩ នៃប្រកាសលេខ ១០៩ កប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារត្រូវបានកែសម្រួលដូចតទៅ :

**ប្រការ ៧ ថ្មី.-ការផ្តល់តាវកាលិកសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន**

៧.១ រយៈពេលនៃការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន ត្រូវបានកំណត់ដូចតទៅ :

- រយៈពេលនៃការសម្រាកព្យាបាលមុខរបួស ឬជំងឺវិជ្ជាជីវៈនៅក្នុងមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាល
- រយៈពេលនៃការសម្រាកព្យាបាលក្រោយពេលមុខរបួសជាសះស្បើយតាមវេជ្ជបញ្ជា។

៧.២ ក្នុងរយៈពេលនៃការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន ដូចមានចែងក្នុងវាក្យខ័ណ្ឌ ៧.១ ខាងលើ កម្មករនិយោជិតដែលរងគ្រោះដោយហានិភ័យការងារ មានសិទ្ធិទទួលបានតាវកាលិក ពីបេឡាជាតិរបបសន្តិសុខសង្គម ដូចតទៅ :

- ប្រាក់បំណាច់ប្រចាំថ្ងៃ ដែលត្រូវផ្តល់ជូនគិតចាប់ពីថ្ងៃទីពីរ បន្ទាប់ពីកាលបរិច្ឆេទ នៃការកើតឧបទ្ទវហេតុបណ្តាលឱ្យទទួលរងនូវហានិភ័យការងារ
- ប្រាក់ឧបត្ថម្ភសម្រាប់អ្នកថែទាំជនរងគ្រោះ ក្នុងរយៈពេលសម្រាកព្យាបាលនៅមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាល។

៧.៣ ប្រាក់ឈ្នួលថ្ងៃធ្វើការងារដំបូងរបស់ជនរងគ្រោះថ្នាក់ការងារ ត្រូវនៅក្នុងបន្ទុករបស់និយោជក។

៧.៤ ប្រាក់បំណាច់ប្រចាំថ្ងៃ សម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្នត្រូវស្មើនឹង ៧០ (ចិតសិប) ភាគរយ នៃប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ។ ប្រាក់ឧបត្ថម្ភសម្រាប់អ្នកថែទាំនៅមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលត្រូវស្មើនឹង ៥០ (ហាសិប) ភាគរយ នៃប្រាក់បំណាច់ប្រចាំថ្ងៃរបស់ជនរងគ្រោះ។

៧.៥ ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន ត្រូវផ្តល់ជូនជនរងគ្រោះរហូតដល់មុខរបួសជាសះស្បើយ។

**ប្រការ ៩ ថ្មី.- ប្រាក់បន្ថែមសម្រាប់អ្នកចាំថែរក្សាជនរងគ្រោះ**

កម្មករនិយោជិត ដែលទទួលរងហានិភ័យការងារបណ្តាលឱ្យបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ ដែលតម្រូវឱ្យមានអ្នកចាំថែរក្សា មានសិទ្ធិទទួលការឧបត្ថម្ភបន្ថែមស្មើនឹង ៥០ (ហាសិប) ភាគរយនៃប្រាក់ធនលាភរបស់ជនរងគ្រោះ។ សិទ្ធិទទួលបានអ្នកចាំថែរក្សា ត្រូវសម្រេចដោយនាយក ប.ស.ស អនុលោមទៅតាមការវាយតម្លៃរបស់គណៈកម្មការវេជ្ជសាស្ត្រ ។

**ប្រការ ពីរ.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០

**រដ្ឋមន្ត្រី**

**វង សូត**

**<u>ចម្លងជូន</u> :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យលោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ

  " ដើម្បីជូនជ្រាប "

- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ។

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ :** [illegible] **ក.ប/ប្រ.ក**

## ប្រកាស

## ស្តីពី

## ការកែសម្រួលប្រការ៨ និងប្រការ១០ នៃប្រកាសលេខ១០៩ កប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ

## ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា នីតិកាលទី៤ នៃរដ្ឋសភា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ/បក ចុះថ្ងៃទី ០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ/បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- បានឃើញប្រកាសលេខ ១០៩ កប/ប្រក ចុះថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ
- បានឃើញប្រកាសលេខ១៤០កប.ប្រក ចុះថ្ងៃទី ១៥ខែមិថុនា ឆ្នាំ២០១០ ស្តីពីការកែសម្រួល ប្រការ ៧ និងប្រការ៩ នៃប្រកាសលេខ១០៩កប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ
- យោងតាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម

*អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩*

## សម្រេច

**ប្រការមួយ-.**

ប្រការ ៨ និងប្រការ ១០ នៃប្រកាសលេខ ១០៩កប/ប្រក ចុះថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតារកាលិកហានិភ័យការងារត្រូវបានកែសម្រួលដូចតទៅ:

**ប្រការ៨ថ្មី -.ការផ្តល់តារកាលិកសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍**

៨.១ កម្មករនិយោជិត ដែលទទួលរងហានិភ័យការងារ បណ្តាលឲ្យបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍តិចជាង២០ភាគរយ មានសិទ្ធិទទួលបានប្រាក់វិភាជន៍សម្រាប់ការបាត់បង់សមត្ថភាពការងារ។ ប្រាក់វិភាជន៍នេះត្រូវផ្តល់ជូនជនរងគ្រោះតែម្តងគត់ ដោយគិតតាមរូបមន្តដូចខាងក្រោម៖

វបក = បឈម x កបក x ២០% មតប

- វបក: វិភាជន៍បាត់បង់សមត្ថភាពការងារ
- បឈម: ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃរបស់ជនរងគ្រោះ
- កបក: កម្រិតបាត់បង់សមត្ថភាពការងាររបស់ជនរងគ្រោះ
- មតប: មេគុណតម្លៃបច្ចុប្បន្ន

៨.២ កម្មករនិយោជិតដែលទទួលរងហានិភ័យការងារ បណ្តាលឲ្យបាត់បង់សមត្ថភាពការងារចាប់ពី២០ភាគរយឡើង មានសិទ្ធិទទួលបានធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍។ ប្រាក់ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ត្រូវបានគិតតាមរូបមន្តដូចខាងក្រោម៖

ធល = បឈម x [កបក-១/៥កបក]

ធល: ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារ

៨.៣ ប្រាក់ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ ត្រូវចាត់ទុកជាបណ្តោះអាសន្នជានិច្ច ។ បេឡាជាតិរបបសន្តិសុខសង្គម ត្រូវរៀបចំឲ្យមានការពិនិត្យសុខភាព និងសមត្ថភាពការងារ អ្នករងគ្រោះឡើងវិញក្នុងរយៈពេល១(មួយ) ឆ្នាំយ៉ាងយូរ ។ ជនរងគ្រោះដែលទទួលបានធនលាភត្រូវមានកាតព្វកិច្ចមកពិនិត្យសុខភាព តាមការកំណត់របស់ បេឡាជាតិរបបសន្តិសុខសង្គម។

៨.៤ ប្រាក់ធនលាភសម្រាប់ការពាត់បង់សមត្ថភាពការងារជារអចិន្ត្រៃយ៍ ត្រូវបានពិនិត្យឡើងវិញជារៀងរាល់ឆ្នាំ ដោយអនុលោមតាមអត្រាអតិផរណា ដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

៨.៥ កម្រិតនៃការបាត់បង់សមត្ថភាពការងារ ត្រូវបានកំណត់នៅក្នុង ឧបសម្ព័ន្ធ ២ នៃប្រកាសលេខ ១០៩ កប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតារកាលិកហានិភ័យការងារ ។

៨.៦ មេគុណតម្លៃបច្ចុប្បន្ន ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធ ៣ នៃប្រកាសលេខ ១០៩កប/ប្រក ចុះថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតារកាលិកហានិភ័យការងារ។

**ប្រការ១០ ថ្មី-. ប្រាក់វិភាជន៍ជាសោហ៊ុយបូជាសព**

ក្នុងករណីដែលទទួលរងហានិភ័យការងាររហូតបណ្តាលឲ្យបាត់បង់ជីវិត អ្នកទទួលរ៉ាប់រងក្នុងការចាត់ចែងបូជាសព ត្រូវបានផ្តល់ប្រាក់វិភាជន៍ជាសោហ៊ុយបូជាសព ដែលមានចំនួន ៤.០០០.០០០ (បួនលាន) រៀល។ ប្រាក់វិភាជន៍នេះត្រូវតែផ្តល់ជូនទៅជនដែលទទួលបន្ទុកផ្ទាល់ក្នុងការចាត់ចែងបូជាសពជនរងគ្រោះ ។

**ប្រការពីរ-.**

ប្រកាសនេះមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១១

**រដ្ឋមន្ត្រី**

**វង សូត**

ចម្លងជូនៈ

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ "ដើម្បីជូនជ្រាប"
- ឯកសារ និងកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងព័ត៌មាន

MINISTRY OF INFORMATION

លេខ...៩៧៤.........ព.ម.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី...១១...ខែ...កត្ដិក...ឆ្នាំ...២០១១

# ប្រកាស

## រដ្ឋមន្ត្រីក្រសួងព័ត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា។
- បានឃើញព្រះរាជក្រឹត្យ ន.ស.រ.ក.ត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា។
- បានឃើញព្រះរាជក្រមលេខ ០២/ន.ស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី។
- បានឃើញព្រះរាជក្រមលេខន.ស.រ.ក.ម/០១៩៦/១៥ចុះថ្ងៃទី២៤ខែមករាឆ្នាំ១៩៩៦ប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន។
- បានឃើញព្រះរាជក្រមលេខ ន.ស.រ.ក.ម /០៨៩៥/០៧ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ប្រកាសឲ្យប្រើ ច្បាប់ស្តីពីរបបសារព័ត៌មាន។
- បានឃើញអនុក្រឹត្យលេខ៧០ អ.ន.ក្រ.ប.ក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ១៩៩៩ស្តី ពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាន។
- បានឃើញអនុក្រឹត្យលេខ៧១ អ.ន.ក្រ.ប.ក ចុះថ្ងៃទី១៣ ខែ កក្កដា ឆ្នាំ២០០៧ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋានរដ្ឋបាលសោតទស្សន៍ ជាអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និង អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ របស់ក្រសួងព័ត៌មាន។
- បានឃើញប្រកាសរបស់ក្រសួងព័ត៌មានលេខ ៦២៥ / ០៩ ពម.ប្រក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៩ ស្តីពីការអនុញ្ញាតឲ្យបោះពុម្ពផ្សាយព្រឹត្តិបត្រ "**បេឡាជាតិរបបសន្តិសុខសង្គម**" ដោយមានលោក **ជាវ ប៊ុនរិទ្ធ** ជាចាងហ្វាងការផ្សាយ។
- បានឃើញលិខិតរបស់លោក**ជាវ ប៊ុនរិទ្ធ** ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១០ស្តីពីសំណើសុំបន្តអាជ្ញាប័ណ្ណព្រឹត្តិបត្រ "**បេឡាជាតិរបបសន្តិសុខសង្គម**" ។

## សម្រេច

**ប្រការ១ :** អនុញ្ញាតឲ្យព្រឹត្តិបត្រ "**បេឡាជាតិរបបសន្តិសុខសង្គម**" បន្តអាជ្ញាប័ណ្ណបោះពុម្ពចែកផ្សាយដោយមានលោក**ជាវ ប៊ុនរិទ្ធ** ជាចាងហ្វាងការផ្សាយដែលមានទីស្នាក់ការស្ថិតនៅអាគារលេខ០៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

**ប្រការ២:** រាល់ដំណើរការបោះពុម្ពចែកផ្សាយត្រូវគោរពតាមរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីរបបសារព័ត៌មាន ក្រមសីលធម៌វិជ្ជាជីវៈអ្នកសារព័ត៌មាន ត្រូវដាក់អាស័យដ្ឋានទីចាត់ការព្រឹត្តិបត្រ ឈ្មោះចាងហ្វាងការផ្សាយ និងឈ្មោះអាស័យដ្ឋានរោងពុម្ព នៅលើទំព័រព្រឹត្តិបត្ររបស់ខ្លួន ព្រមទាំងយកព្រឹត្តិបត្រមួយចំនួនមកតម្កល់ទុកនៅនាយកដ្ឋានមណ្ឌលព័ត៌មាននៃអគ្គនាយកដ្ឋានព័ត៌មាន និង សោតទស្សន៍ នៃក្រសួងព័ត៌មាន និងចំនួន ០២ ច្បាប់ តម្កល់ទុកនៅបណ្ណាល័យជាតិ ។

**ប្រការ៣ :** ក្នុងករណីប្រព្រឹត្តល្មើសដូចមានចែងក្នុងប្រការ១ និងប្រការ២ ខាងលើសាមីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន។

**ប្រការ៤ :** ប្រកាសនេះមានប្រសិទ្ធភាពរយៈពេល ០១ឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ប្រការ៥ :** អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ នៃក្រសួងព័ត៌មាន និងចាងហ្វាងការផ្សាយព្រឹត្តិបត្រ "**បេឡាជាតិរបបសន្តិសុខសង្គម**" ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាពខ្ពស់ ។

**រដ្ឋមន្ត្រី**

ខៀវ កាញារីទ្ធ

<u>ចម្លងជូន</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងយុត្តិធម៌
- គ្រប់សមាគមអ្នកសារព័ត៌មានកម្ពុជា "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន
- ឯកសារ-កាលប្បវត្តិ

**ក្រសួងព័ត៌មាន** អាស័យដ្ឋាន អគារលេខ ៦២, មហាវិថីព្រះមុនីវង្ស, សង្កាត់ស្រះចក, ខណ្ឌដូនពេញ, រាជធានីភ្នំពេញ.ទូរស័ព្ទ/ទូរសារ : (០២៣) ៤៣០ ៦០៤ , (០២៣) ៤២៧ ៤៧៥

MINISTRY OF INFORMATION : #62, Preah Monivong Blvd. Sangkat Sras Chork, Khan Daun Penh, Phnom penh. Phone/ Fax : (023) 430 604 , (023) 427 475

# អាសយដ្ឋានមន្ទីរពេទ្យដែលបានចុះកិច្ចសន្យាជាមួយ ប.ស.ស

| ល.រ | ឈ្មោះមន្ទីរពេទ្យ | ឡានសាម៉ុយ | ទូរស័ព្ទទាន់ហេតុការណ៍ | ភ្នាក់ងារ ប.ស.ស |
|---|---|---|---|---|
| ០១ | មន្ទីរពេទ្យកាល់ម៉ែត | ១១៩ | ០២៣ ៤២ ៦៩ ៤៨ | ០៩៧ ៦៨៧ ២៤២ ៦ |
| ០២ | មន្ទីរពេទ្យព្រះកុសុមៈ | ១១៩ | ០១២ ៦៥៧ ៦៥៣ | ០៩៧ ៦៨៧ ២៤២ ៩ |
| ០៣ | មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត | ១១៩ | ០២៣ ២១៧ ៧៦៤ | ០៩៧ ៦៨៧ ២៤២ ៧ |
| ០៤ | មន្ទីរពេទ្យព្រះអង្គឌួង | | ០១១ ៧៥៥ ១១៩<br>០៧៧ ៥៥០ ០១៧ | |
| ០៥ | មន្ទីរពេទ្យជ័យជំនះ | ០១៥ ៩១៩ ១១៩ | ០១២ ៩១២ ៥២៣ | ០៩៧ ៦៨៧ ២៤២ ៨ |
| ០៦ | មន្ទីរពេទ្យបង្អែកកំពង់ស្ពឺ | ០១៦ ៦៩៦ ៤៨០ | ០២៥ ៩៨៧ ៣១៣ | ០៩៧ ៧៨៣ ៩៣៩ ១ |
| ០៧ | មណ្ឌលសុខភាពបែកចាន | ០១២ ១៧៥ ៨២៨ ៥<br>០៩៧ ៤៩៩ ៨៩៣ ៦ | ០១២ ៨៩៤ ២៦០ | ០៩៧ ៧៨៣ ៨៧៦ ៥ |
| ០៨ | មន្ទីរពេទ្យបង្អែកអង្គស្នួល | ០១២ ៥៨១ ៦៣៩ | ០១២ ៨៩៤ ២៦០ | |
| ០៩ | មន្ទីរពេទ្យបង្អែកស្វាយរៀង | ០៤៤ ៩៤៥ ១១១ | ០១២ ៩៥៣ ៩៧៥ | ០៩៧ ៧៨៣ ៨៧៥ ៩ |
| ១០ | មន្ទីរពេទ្យបង្អែកជីទូ | ០១១ ៣៩៤ ១៧៨ | ០១២ ៨០៥ ២៣៦ | |
| ១១ | មន្ទីរពេទ្យបង្អែកកំពង់ឆ្នាំង | ០២៦ ៩៨៨ ១១១ | ០១៥ ២៥០ ១១១ | |
| ១២ | មន្ទីរពេទ្យបង្អែកកំពង់ត្រឡាច | ០៨៥ ៥៨៧ ៧៥៧ | ០៨៥ ៥៨៧ ៧៩០ | ០៨៨ ៩៧ ២ ១០១ ៦ |
| ១៣ | មន្ទីរពេទ្យបង្អែកសៀមរាប | ០១៦ ៨០០ ១១៩ | ០១២ ៩២៥ ០៦១ | ០៨៨ ៩៧ ២ ១០១ ២ |
| ១៤ | មន្ទីរពេទ្យបង្អែកអូរជ្រៅ | ០១២ ៧៨៦ ២៨៦ | ០៨៩ ៨៣៧ ៦៣៧ | ០៨៨ ៩៧ ២ ១០១ ៣ |
| ១៥ | មន្ទីរពេទ្យបង្អែកខេត្តមិត្តភាពកម្ពុជា-ជប៉ុន | ០១២ ៩៣២ ៥២១ | ០១២ ៩២៣ ៣៥៤ | |
| ១៦ | មន្ទីរពេទ្យបង្អែកសិរីសោភ័ណ | ០១២ ៩១០ ៤៦៧ | ០១២ ៨៥៤ ៩៨៣ | |
| ១៧ | មន្ទីរពេទ្យបង្អែកខេត្តព្រះសីហនុ | ០១៦ ៦៨៦ ៨៤៣ | ០១២ ៧១២ ៦៤៦ | ០៨៨ ៩៧ ២ ១០១ ៤ |
| ១៨ | មន្ទីរពេទ្យ CT ( ខេត្តព្រះសីហនុ ) | ០៨៩ ៨៨ ៦៦៦៦<br>០៨៥ ៨៨ ៦៦៦៦ | ០៨១ ៨៨ ៦៦ ៦៦ | |
| ១៩ | មន្ទីរពេទ្យបង្អែកស្រុកជើងព្រៃ | ០១២ ៦៦៧ ៤៨៦<br>០៨៨ ៧៧៤ ៤៧៨ ៨ | ០១៧ ៤២៣ ៥៤៨ | |
| ២០ | មន្ទីរពេទ្យបង្អែកស្រុកពញាក្រែក | ០៨៨ ៧៧៤ ៤៧១ ១<br>០១១ ៦៦៩ ៤០៨<br>០៨៥ ៤១៤ ៨១៩ | ០៨៥ ៤១៤ ៨១៩ | ០១២ ៥២០ ៧៦៧ |

| | | | | |
|---|---|---|---|---|
| ២១ | មន្ទីរពេទ្យបង្អែកស្រុកត្បូងឃ្មុំ | ០៨៨ ៧៧ ៨៤ ៧០០ | ០១២ ៨៩៥ ៦៥០<br>០១១ ៨៦២ ០៣៩ | |
| ២២ | មន្ទីរពេទ្យបង្អែកខេត្តក្រចេះ | ០៧២ ២១០ ៣៩១<br>០១២ ៨២២ ៣៩១ | ០១២ ៩៣១ ៨៦៨ | ០៩៧ ៧៩៧ ៨៩៩ ៩<br>០៩៧ ៩៨៩ ៦៦៩ ១ |
| ២៣ | មន្ទីរពេទ្យបង្អែកស្រុកឆ្លូង | ០៩២ ៨៦៦ ៤១៣<br>០១៧ ៩០៩ ៦៥៣ | ០១២ ៣៦៧ ៧០២ | |
| ២៤ | មន្ទីរពេទ្យបង្អែកស្រុកស្នួល | ០៩៧ ៧៥២ ៧៩៩ ៦<br>០១២ ៥២៧ ៩៩ | ០៩៧ ៦៥៩ ៧ ២៩ ៩ | |
| ២៥ | មន្ទីរពេទ្យបង្អែកអ្នកលឿង | ០១២ ៧៩៥ ៣១៩ | ០១២ ៦៦០ ៨១៥ | |
| ២៦ | មន្ទីរពេទ្យបង្អែកព្រៃវែង | ០៩៧ ២៣៤១៧៨២<br>០១២ ៦៥៨ ៣០៣ | ០១២ ៦៥៨ ៣០៣ | |
| ២៧ | មន្ទីរពេទ្យបង្អែកកោះធំ | ១១៩<br>០១៧ ៧២២ ០៦៥ | ០២៣ ៣៥១ ១៩៨ | |
| ២៨ | មន្ទីរពេទ្យបង្អែកស្រុកស្អាង | ១១៩<br>០១៧ ៧២២ ០៦៥ | ០២៣ ៣៥១ ១៩៨ | |
| ២៩ | មន្ទីរពេទ្យខេត្តតាកែវ | ០១២ ៩៣៥ ៨១៤<br>០១២ ១ ៧២៨ ៣៤៨ | | |
| ៣០ | មន្ទីរពេទ្យបង្អែកបាទី | ០១២ ៧២៤ ០៩៣<br>០៩៧ ៦៤៧៤ ៣០៣ | ០៣២ ៦៩០ ១៩ ៣៩ | |

តមកពីទំព័រ ១៩

### មេធិកាសាគីពាក់ព័ន្ធ

-ប.ស.ស គួរផ្សព្វផ្សាយឱ្យបានទូលំទូលាយ អំពីគោលការណ៍ ប.ស.ស ទៅដល់ក្រុមហ៊ុន ឬសហគ្រាស និងកម្មករនិយោជិត។

-អនុវត្តការពានាផ្សេងៗទៀត ដូចជាធានាថៃទាំសុខភាពទូទៅនិងប្រាក់សោធន។

-ចំពោះនិយោជកវិញគួរចុះឈ្មោះឱ្យបានគ្រប់រោងចក្រនៅក្នុងប្រទេស សហគ្រាសចាប់ពី០៨នាក់ឡើងទៅ ។

-ត្រូវបញ្ជូនព័ត៌មានចំពោះអ្នកដែលមានគ្រោះថ្នាក់ការងារមក ប.ស.ស ឱ្យបានលឿន។

-ត្រូវផ្តល់ឱ្យកម្មករនិយោជិតនូវអ្វីដែលធ្លាប់ឱ្យជៀសវាងមានការភ័ន្តច្រឡំថាខ្លួនគេចផុតពីកាតព្វកិច្ចទាំងស្រុងដូចជា៖ -ប្រាក់រង្វាន់ទៀងទាត់ -ពេលកម្មករឈឺ -ការឈប់ដោយមានប្រាក់ឈ្នួល -រីឯសហជីព និងកម្មករនិយោជិត ត្រូវរីករាយនឹងចូលរួមផ្តល់ព័ត៌មាន ចំពោះរោងចក្រណាដែលមិនទាន់បានចុះបញ្ជីជាមួយ ប.ស.ស។

-ត្រូវសិក្សាឱ្យបានយល់ច្បាស់អំពី ប.ស.ស។ -សហការជាមួយក្រុមហ៊ុន ដើម្បីទទួលសេវា និងបង់លុយចូល ហើយនិងទទួលលុយពី ប.ស.ស។

-ត្រូវរាយការណ៍នូវចំនួនកម្មករ ឬរោងចក្រណាដែលលាក់ចំនួនកម្មករ ទៅ ប.ស.ស។

-ត្រូវរៀបចុះសំបុត្រអាពាហ៍ពិពាហ៍ ប័ណ្ណគ្រួសារ អត្តសញ្ញាណប័ណ្ណ ឬសំបុត្រកំណើតឱ្យបានត្រឹមត្រូវ ដើម្បីទទួលបានសិទ្ធិផ្សេងៗ៕




MINISTRY OF HEALTH
មន្ទីរពេទ្យ មិត្តភាពខ្មែរ-សូវៀត
KHMER-SOVIET FRIENDSHIP HOSPITAL
ផ្លូវ ២៧១ សង្កាត់ ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ


119
ក្រសួងសុខាភិបាល
សាមុយមន្ទីរពេទ្យ ព្រះកុសុមៈ
ERT-15
S.A.M.U AMBULANC